D24826
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ជាមួយ ហ៊ឹម ហ៊ុយ

## អតីតយុទ្ធជនវរៈសេនាតូច១១២កងពល៧០៣

## និងជាប្រធានក្រុមយុទ្ធជនការពារនៅមន្ទីរស-២១

## នៅភូមិអន្លង់តាសាន ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្ដាល

## ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១

## ដោយ ហ៊ុយ វណ្ណៈ

វណ្ណៈ ចឹងដំបូងខ្ញុំសុំពូ សព្វថ្ងៃពូនៅនេះគេហៅភូមិអីគេ?

ហ៊ុយ ភូមិអន្លង់តាសាន ឃុំព្រែកស្តី ស្រុកកោះធំ ។

វណ្ណៈ ខេត្តអីដែរពូ?

ហ៊ុយ ខេត្តកណ្ដាលដែរ ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីប្រវត្តិរបស់ពូតាំងពីការងាររបស់ពូដែលពូបានធ្វើម៉ោ ហើយអ៊ីដែលពូបានចងចាំ?

ហ៊ុយ កាលពី គេប្រមូលម៉ោធ្វើទាហានម៉ោ គេថាយកម៉ោធ្វើទ័ពនោះណាស់ តាំងពីដើមឆ្នាំ៧៣ ដើមឆ្នាំ៧៣គេប្រមូលទាំងអស់អ្នកដែលមានអាយុគ្រប់គេកេណ្ឌយកម៉ោធ្វើទ័ព ។ ដំបូងខ្ញុំម៉ោនៅស្រុក ប្រមូលយកម៉ោឲ្យម៉ោនៅកងទ័ពស្រុក នៅស្រុកគេឲ្យរៀន ឲ្យរៀនបច្ចេកទេសណឹង ។ រៀនបច្ចេកទេសហើយគេបញ្ជូនឲ្យម៉ោតំបន់ ឲ្យម៉ោតំបន់ហើយបានគេបញ្ជូនទៅក្រាំងយ៉ូវទៅ ។ ដល់ពេលគេបញ្ជូនណឹងសុំគេ... មើលទៅ មិនទៅទេកន្លែងណឹង ។ សុំគេម៉ោផ្ទះវិញ ម៉ោស្នាក់នៅវត្តកំពង់សំបួរនេះ ។ សុំគេទៅផ្ទះក៏គេអត់ឲ្យទៅ...ដឹងធ្វើម៉េចទៀតបើសុំគេទៅផ្ទះហើយគេអត់ឲ្យទៅ ។ ទៅជាមួយគេទៀតទៅ ទៅដល់ព្រៃល្វា នៅវត្តអី! គេហៅវត្តថ្មីណោះខាងជើងព្រៃល្វាណឹង ។ បាន...គេរើសបញ្ចូលកង គេហៅកងទ័ពភូមិភាគពិសេសណឹង ។ បញ្ចូលនៅណឹង ។ ទៅរៀនបច្ចេកទេស រៀននយោបាយគេណឹង រៀនបច្ចេកទេសនយោបាយគេហើយបានប៉ុន្មានខែ គេបញ្ជូនឲ្យទៅវៃ ។ ម៉ោវៃណឹងមិន

មិនដែលស្គាល់គ្រាប់កាំភ្លើយ៉ាងម៉េចទេ កាំភ្លើងក៏មិនដឹង គេឲ្យរៀនធើ ដោះរៀនបាញ់ អីណឹង ដល់ហើយបានគេបញ្ជូនឲ្យទៅវៃនៅផ្លូវជាតិលេខ២ណឹង ។ ទៅវៃផ្លូវជាតិលេខ២... ដល់ហើយក្រោយម៉ោដកចេញទៅវិញម៉ោគេបញ្ជូនទៅឲ្យទៅនៅទន្លេបាទីទៀត ។ ដល់ទៅនៅទន្លេបាទីបានបកពីទន្លេបាទីម៉ោ ម៉ោនៅអីបឹង៥០០នេះ នៅស្ពានភ្នំនេះ ។ នៅស្ពានភ្នំរៀន គេឲ្យរៀនបច្ចេកទេសទៀត រៀនបច្ចេកទេសហើយបានគេដកយកទៅឲ្យវៃណឹងទៀត វៃនៅអីវត្តអ្នកតាឃ្លាំងមឿងណឹង ។ ដល់ហើយដកពីណឹងម៉ោបានបញ្ជូនម៉ោនៅទន្លេ ។ នៅទន្លេបានគេឲ្យម៉ោវៃនៅថ្នល់ជាតិ ម៉ោទន្លេអី ម៉ោនៅអាបឹង៥០០ ស្ពានភ្នំណឹងទៀត ដល់ហើយបញ្ជូនពីណឹងទៅ គេឲ្យទៅវៃតាមផ្លូវជាតិលេខ២១ វៃផ្លូវជាតិលេខ២១យើងលើព្រែកតូចណឹង ។ ដល់វៃកន្ទែងណឹង វៃហើយដកម៉ោវិញបានម៉ោ ម៉ោវៃណែ ត្រើយខាងកើត តាមដងទន្លេបាសាក់នេះ អាតាមវត្ត អាសណ៌ៃ កោះអន្លង់ចិននេះ ។ វៃណឹងដល់ហើយឈឺ ។ ឈឺអាចៃពស់វាខាំពេញខ្លួន ស៊ីបាយក៏មិនកើត ដេកក៏មិនកើត អីក៏មិនកើត ដេកស្មៀកតាកន្សែង សុំគេចេញម៉ោក៏គេមិនឲ្យម៉ោ សុំទៅដេកពេទ្យក៏គេអត់ឲ្យម៉ោ ។ យូរណាស់ ដល់ក្រោយម៉ោបានគេបញ្ជូនម៉ោឲ្យពេទ្យ ឲ្យម៉ោដេកពេទ្យ ។ ដេកពេទ្យដល់ហើយចេញពីពេទ្យម៉ោគេចម៉ោផ្ទះ...មើលទៅនៅមិនបានទេ ម៉ោផ្ទះហើយ ។ ម៉ោផ្ទះ ម៉ោនៅផ្ទះបានម៉ាងៃ ២ងៃ ប្រធានភូមិបេះតាសួរ...សួរថ្ងៃណាអ្អែងទៅវិញ? ខ្ញុំថាស្អែកខ្ញុំទៅវិញ ។ ស្អែកក៏មិនទាន់ទៅនៅផ្ទះទៀត គោលបំណងគឺមិនទៅវិញទេ! ម៉ោនេះគឺម៉ោនៅផ្ទះ ឈប់ទៅហើយ ។ ដល់ប្រធានភូមិសួរច្រើនដង រហូតដល់៥ថ្ងៃទៅវិញ ។ មើលទៅមិនកើតទេ ព្រោះប្រធានភូមិរករឿង តាម៉េចៗគេប្តឹងឃុំ ឃុំចាប់...ទៅវិញ ។ ទៅវិញទៅដល់ពេទ្យ ល្ងាចណឹងធ្មើឈ្មោះធ្មើអីហើយ ព្រលឹមឡើងពេទ្យបញ្ជូនឲ្យទៅកង ។ ហីកងនៅអីនេះណោះនៅអីស្ពានភ្នំណោះ ។ ដល់តាវៃក្រោយទៀត គេបញ្ជូនទៅវៃក្រោយទៀត ដល់ហើយរត់ម៉ោវិញទៀត ។ អឺម៉ោដេកពេទ្យ ដេកពេទ្យរត់ម៉ោផ្ទះទៀត ។រត់៣ដងបានកងរយគេបញ្ជូនឲ្យម៉ោរៀនសាលាសេរីនៅកណ្តាលកោះ ។ អាណឹងអន្តភាពដកម៉ោវិញហើយ ម៉ោនៅកោះអន្លង់ចិន ។

វណ្ណៈ ហើយយ៉ាងម៉េចទៀត?

ហ៊ុយ បាទ! ដល់ហើយបានគេបញ្ជូនអឺ ពេលរៀនសូត្រហើយ កងវរៈថា អាស៎ កងវរយថាខ្ញុំអស់សមត្ថភាព គាត់អស់សមត្ថភាពកសាងខ្ញុំហើយ ព្រោះខ្ញុំអាវល់តារត់ម៉ោផ្ទះតឡូវ ប្រគល់ឲ្យកងវរៈធើយ៉ាងម៉េចធ្វើទៅ ។ ដល់ហើយក្រោយម៉ោបានកងវរៈបញ្ជូនខ្ញុំ លែងឲ្យខ្ញុំនៅក្នុងកងណឹង គាត់ឲ្យខ្ញុំម៉ោនៅអឺ...គេហៅកងសម្រុកគោនោះ ។ ឲ្យម៉ោនៅកងសម្រុក នៅកងសម្រុកបានប៉ុន្មានខែ វៃនៅ...អឺទេត្រើយខាងកើតបំ បំកោះអន្ទង់ចិននេះ ដឹងគេហៅស្អីគេទេ ។ ដល់តាវៃកន្លែងណឹងហើយម៉ោវៃស្រែអំពិលនេះទៀត ។ ដល់ក្រោយម៉ោបញ្ជូនពួកខ្ញុំណឹងទៅទន្លេមេគង្គ ។ ដល់តាបញ្ជូនទៅទន្លេមេគង្គខ្ញុំអត់បាននៅវៃនៅអីទៀតទេ បានកងវរៈដកខ្ញុំចេញឲ្យខ្ញុំទៅនៅកងស៊ើបការណ៍វិញ ។ ទៅនៅកងស៊ើបការណ៍រហូត ដើរស៊ើបការណ៍អាកន្លែងព្រែកអ្នកតាវ៉ាំង ស៊ើបការណ៍តាមទន្លេមេគង្គ អឺ តាមទន្លេបាសាក់ ទន្លេមេគង្គណឹង...រហូតដលវៃភ្នំពេញវៃអីណឹងទៅ ។

វណ្ណៈ ដល់ពេលវៃភ្នំពេញហើយពូទៅណាទៀត?

ហ៊ុយ បាទ! ពេលវៃភ្នំពេញហើយ ពេលវៃភ្នំពេញខ្ញុំរបួស ។ របួសដេកពេទ្យតាប៉ុន្មានខែ ៣-៤-៥ខែបានជា បានទៅកងវិញ ។ទៅកង កងនៅកន្លែងការពារទឹកល្អក់អឺស្ថានីយ៍បូមទឹកកន្លែងទឹកល្អក់នេះ ។ ដល់ហើយបានគេ អឺនៅកន្លែងណឹងប៉ុនថាគេឲ្យធ្វើដំរាលដី ម៉ោធ្វើស្រែនៅកន្លែងអឺឡឥដ្ឋចាក់អង្រែនេះ ។ ហីក្រោយម៉ោបានគេដកចេញពី គេដកទាំងកងណឹងម៉ោ ឲ្យម៉ោនៅនេះ អឺគេហៅស្អីគេ តាមស៊ឹងព្រែកត្នោតនេះគេហៅអីគេ ឲ្យម៉ោនៅធ្វើដីធ្វើស្រែណឹង ។ ដល់ក្រោយម៉ោបាន **តាហ៊ី** នោះតាហ៊ីកន្ទួញនោះ កងវរៈនោះគាត់នៅអឺផ្សារថ្មីណឹង គាត់ឲ្យនីរសារគាត់ម៉ោយក ហៅខ្ញុំទៅ ប្រាប់ថាឲ្យខ្ញុំផ្លាស់អង្គភាព ថាទៅនៅអង្គភាពអាម៉ារីន ។ ដល់យប់ណឹងបានតាហ៊ីណឹងឌុបខ្ញុំម៉ោ ឌុបកង់ខ្ញុំម៉ោ យកម៉ោចូលកន្លែងមន្ទីរស-២១ ។ ពេលគាត់ឌុបខ្ញុំម៉ោ សួរខ្ញុំដឹងខ្លួនឯងមានរឿងអីអត់? ហីចុះក្រែងបងឯងឲ្យខ្ញុំទៅអង្គភាពអាម៉ារីន? អ្ហឺ!អង្គភាពអាម៉ារីនអី! ។ទៅកង់តាដឹងទេ! ទៅកង់តាដឹទេ! ។ ខ្ញុំថាចុម ទៅកង់ដឹងម៉េច? ខ្ញុំអត់មានដឹងមានរឿងអីផង! ហីឈប់ម៉ាត់ជាមួយគាត់ទៅ ។ ដល់ហើយខ្ញុំម៉ោ ចេះតាជិះកង់តាមក្រោយគាត់ណឹង កន្ទុយកង់គាត់ណឹងម៉ោរហូត ហើយឌុបខ្ញុំចូលទៅកន្លែងណឹងបាដោយ ។

វណ្ណៈ ក្នុងឆ្នាំណាដែរពូទៅដល់ស-២១ណឹង?

ហ៊ុយ ឆ្នាំប៉ុន្មានទេ ឆ្នាំ៧៧ណឹង ។

វណ្ណៈ ហើយយ៉ាងម៉េចទៀតទៅពូ ដល់ស-២១?

ហ៊ុយ ដល់ហើយគាត់ឲ្យខ្ញុំចូលនៅណឹង គេឲ្យនៅដេក នៅស៊ីនៅណឹង ប៉ុន្មាន៣-៤ថ្ងៃ បានគេឲ្យខ្ញុំយាម ។ យាមណឹងបានប៉ុន្មានថ្ងៃបាន គេខ្ចីពីកងឲ្យទៅទៀតហើយ ខ្ចីទ័ពពីកងយកទៅការពារទៀតណឹងហើយ ។

វណ្ណៈ គេយកទៅការពារអីគេ?

ហ៊ុយ ការពារគុកគេណឹង ។

វណ្ណៈ បន្ទាប់ម៉ោពូធ្វើអីទៀត?

ហ៊ុយ នៅកន្លែងណឹងរហូតដល់ហើយបានពាក់កណ្ដាលឆ្នាំ៧៨ បានគេដកខ្ញុំឲ្យម៉ោនៅធ្វើស្រែខាងត្បូងជើងឯក ។ រហូតដល់បែកបានគេប្រមូល ខុចណឹងម៉ោប្រមូលគ្នាគេម៉ោពីភ្នំពេញម៉ោអស់ ម៉ោប្រមូលពួកខ្ញុំពួកអីអស់...។ ទៅព្រៃទៅនៅជាមួយគេបានប៉ុន្មានខែម៉ោផ្ទះវិញ ។

វណ្ណៈ ពូមានចាំអីព្រឹត្តិការណ៍ក្នុងចន្លោះដែលពូរៀបរាប់ណឹងផ្សេងទៀតដែរ?

ហ៊ុយ អត់ចាំ ។

វណ្ណៈ ចឹងបន្ទាប់ពីម៉ោផ្ទះ ម៉ោវិញម៉ោពូមានធ្វើអីទៀតដែរ?

ហ៊ុយ អត់មានធ្វើអីទៀតទេ ។

វណ្ណៈ ចឹងខ្ញុំសុំសួរបកពូវិញ តាមឆ្នាំដែលពូចូលធ្វើក្នុងកន្លែងនិមួយៗ ។ ពូចូលទៅធ្វើទ័ពណឹងពូត្រូយ៉ាងម៉េចដែរបានពូចូលទៅធ្វើទ័ពណឹង កាលដំបូងឡើយណាស់?

ហ៊ុយ អត់មានត្រូអីទេ ព្រោះគេកាលណឹងគេគាគ្រប់អាយុគេអត់ឲ្យការ ហីម៉ែឪខ្ញុំមែនឲ្យទៅធ្វើទ័ពធ្វើអីទេ ។ ដល់គេអត់ឲ្យការជឹងធ្វើយ៉ាងម៉េច! ហីមួយកំណែនគេប្រមូលចឹងគេប្រមូលទាំងអស់ ម៉ាភូមិគេប្រមូលយកទៅទាំងអស់ៗទៅហ្នឹង ។

វណ្ណៈ ហីកាលពូចូលធ្វើណឹងអាយុប៉ុន្មានដែរពូ?

ហ៊ុយ អាយុដូច១៧-១៨ឆ្នាំហើយ ។

វណ្ណៈ ហីពូចូលតាមរយៈអ្នកណាដែរ ពូរៀបរាប់ពីរបៀបដែលពូចូលតាមួយៗ?

ហ៊ុយ ចូលកាលណឹងប្រធានភូមិហៅខ្ញុំទៅ ប្រធានភូមិគេប្រមូលទៅ បាទ ។

វណ្ណៈ ហីពូចូលទៅណឹង ទៅដល់ទ័ពស្រុកពីណាអ្នកបញ្ជូនពូទៅរៀនបច្ចេកទេសរៀនអីទៀតណឹង?

ហ៊ុយ បញ្ជូនណឹងនៅលើគណៈសាលាគេ ។ ឈ្មោះអីទេភ្លេចអស់ហើយ ។ គណៈសាលាគេប្រមូលពួកខ្ញុំណឹងយកទៅទៀត ទៅទ័ពទៅ៧០៣ណឹង កងពល១២គេមុនណឹង ។

វណ្ណៈ ហីពេលដែលពូទៅទ័ពស្រុកណឹង ទាហានគេមានលេខមានវរៈអីប៉ុនៅ?

ហ៊ុយ អត់មានទេ ។

វណ្ណៈ ហីរហូតដល់ពេលណាបានកង តាមលំដាប់គេមានលេខមានអីគេ?

ហ៊ុយ នៅពេលដែលគេបញ្ជូនខ្ញុំទៅកងទ័ពណឹងបានគេ មានលេខមានអីគេ ។

វណ្ណៈ កាលណឹងពូនៅក្នុងវរៈអី ក្រុមអី នៅក្នុងកងពលណាដែរ?

ហ៊ុយ នៅ...អ៊ឺ...មិនដឹងប៉ុន្មានអីប៉ុន្មានទេ ប៉ុនតានៅកងវរៈ១១២ ។

វណ្ណៈ នៅក្នុងកងពល...?

ហ៊ុយ ១២ណឹង ។

វណ្ណៈ ពីណាគេធ្វើប្រធានវរៈពូ ហើយពីណាគេប្រធានកងពល១២?

ហ៊ុយ ភ្លេចឈ្មោះអស់ហើយ ។

វណ្ណៈ ចុះកងពល១១ពីណាគេប្រធាន?

ហ៊ុយ តាណាត ...អេ តាណាតអីអ្នកណាគេទេ...**តាណាត**គាត់បញ្ជាការ...អ្នកណាខ្លះទេភ្លេចអស់ហើយ ។

វណ្ណៈ ពេលដែលពូទៅរៀនបច្ចេកទេសណឹងគេឲ្យពូរៀនពីអីខ្លះពូ?

ហ៊ុយ គេបង្រៀននយោបាយ គេបង្រៀនបច្ចេកទេសខាងយោធាណឹង ។

វណ្ណៈ នយោបាយណឹងគេរៀនលើមុខវិជ្ជាអីខ្លះ?

ហ៊ុយ អ៊ឺ! នយោបាយគេដឹងនិយាយពីស្អីទេ... ។

វណ្ណៈ ពេលដែលពូចេញពីសាលាបច្ចេកទេសហើយពូទៅកន្លែងតំបន់ តំបន់ណឹងមានន័យថាយ៉ាងម៉េចពូ ហើយគេឲ្យយើងធ្វើយ៉ាងម៉េច?

ហ៊ុយ អាណឹងខាងសាលាបច្ចេកទេសតំបន់របស់គេណឹង ។

វណ្ណៈ នៅកន្លែងណាសាលាណឹង?

ហ៊ុយ សាលាណឹងនៅចំមុខមន្ទីរស្រុកកោះធំនេះ នៅមាត់ទន្លេកន្លែងចម្ការល្មុតគេណឹង ក្បែរព្រែក ខាងត្បូងព្រែក ។

វណ្ណៈ ពូមានចាំ...ពីណាគេគណៈតំបន់...នៅសាលាណឹង? គណៈតំបន់គ្រប់គ្រង?

ហ៊ុយ គណៈតំបន់ដឹងឈ្មោះអីហើយទេ ។

វណ្ណៈ ហើយតំបន់ណឹងគេហៅតំបន់អីដែរពូ?

ហ៊ុយ ហៅតំបន់២៥ ។

វណ្ណៈ កាលណឹងមានប្រធានគេឈ្មោះអីតំបន់២៥ណឹង?

ហ៊ុយ ដឹងឈ្មោះអីខ្លះហើយទេ ។

វណ្ណៈ ហើពូម៉ោរៀននៅតំបន់ណឹង ចូលកន្លែងតំបន់២៥ណឹងនៅឆ្នាំណាដែរពូ?

ហ៊ុយ អាណឹងមើល៍ ឆ្នាំប៉ុន្មានទេ...នៅឆ្នាំ៧៣ ។

វណ្ណៈ នៅ៧៣ដដែល ។ បន្ទាប់មកពូទៅក្រាំងយ៉ូវ ទៅក្រាំងយ៉ូវណឹងគេឲ្យយើងធ្វើអីទៀតបានគេបញ្ជូនយើងទៅក្រាំងយ៉ូវ?

ហ៊ុយ គេឲ្យទៅទ័ពណឹងហ្នង រៀបជាអង្គភាព ។ ទៅបញ្ចូលគេ គេខ្វះកម្លាំងទ័ពគេណឹង ។

វណ្ណៈ គេបញ្ចូលទៅក្នុងអង្គភាពអីដែរនៅក្រាំងយ៉ូវណឹង?

ហ៊ុយ កងទ័ពណឹងហ្នង ។

វណ្ណៈ កងទ័ពរបស់ខាងណា?

ហ៊ុយ របស់ភូមិភាគពិសេស ។

វណ្ណៈ នៅណឹងមានស្អីខ្លះនៅក្រាំងយ៉ូវណឹង?

ហ៊ុយ អត់មានអីទេ ដើរនៅតាមផ្ទះប្រជាជន ។

វណ្ណៈ ចឹង! ទ័ពពូមុនអស់អត់មាន...?

ហ៊ុយ បន្ទាយអត់មានអីទេ ដើតានៅតាមផ្ទះ ។

វណ្ណៈ ហើយបន្ទាប់ម៉ោពូត្រឡប់ម៉ោផ្ទះវិញ ?

ហ៊ុយ បាទ! ហើយពេលឈឺពេលអីខ្ញុំម៉ោផ្ទះ កាលណឹងម៉ោប្រុងតាមិនទៅវិញព្រោះវៃគ្នា វៃមិននេះសោះ ទិចវៃគ្នាៗ ចឹងខ្លាចណាស់ ខ្លាចស្លាប់! ដល់ម៉ោផ្ទះភូមិនេះវាតឹងតែងដល់ដែរ បើកាលណាយើងមិនទៅ គេចាប់យើងដាក់ឃុំឃាំងយើង ដាក់គុកដាក់អីស្លាប់ ។

វណ្ណៈ ហើយបានពូទៅចេញពីផ្ទះហើយពូទៅ...?

ហ៊ុយ បានខ្ញុំបកម៉ោវិញ ។

វណ្ណៈ ទៅព្រៃល្វាទៀត? ទៅព្រៃល្វាណឹងគេឲ្យពូធ្វើអីទៀតពូ?

ហ៊ុយ អត់ទេនិយាយពីដែលនៅមន្ទីរ អាស់! នៅកន្លែងវត្តកំពុងសំបួរនេះណាស់ គឺខ្ញុំសុំគេម៉ោផ្ទះ សុំគណៈសាលាណឹងម៉ោផ្ទះវិញណាស់ គេអត់ឲ្យខ្ញុំម៉ោផ្ទះ គេបញ្ជូនខ្ញុំទៅព្រៃល្វា ទៅទាំងអង្គភាពណឹង បាទ ។ ដល់ហើយទៅដល់ព្រៃល្វាខាងត្បូង អាស់ ខាងជើងព្រៃល្វាណឹង... គេដកមនុស្សគេដើររើសមនុស្សចឹងទៅ គេឲ្យឈរទាំងជួរៗគេដើររើសមនុស្សដកចេញ អាណាមាឌធំៗគេដាក់ទៅកាំភ្លើងធំ អាណាមាឌតូចៗគេដាក់ទៅខាងថ្មើរជើង បាទ ។

វណ្ណៈ អាណឹងនៅក្នុងអង្គភាពអីដែរ?

ហ៊ុយ អង្គភាពកងវរៈ១១២ណឹង ។

វណ្ណៈ មានលេខហើយកាលណឹង អាណឹងចាប់ពីឆ្នាំណាម៉ោមានលេខណឹង?

ហ៊ុយ លេខរបស់គេមានហើយ ឆ្នាំ...អាណឹងចូលឆ្នាំ៧៨ហើយ ។

វណ្ណៈ ហើយក្រោយម៉ោគេរើសពូចូលទៅខាងភូមិភាគពិសេសទៀត?

ហ៊ុយ បាទ! កងទ័ពភូមិភាគពិសេសហើយណឹង ។

វណ្ណៈ អាណឹងក្នុងវរៈមុិញនៅក្នុងកងទ័ពពិសេសណឹងដែរ?

ហ៊ុយ បាទ!

វណ្ណៈ យ៉ាងម៉េចបានគេឲ្យឈ្មោះថាកងទ័ពណឹងជាកងទ័ពពិសេសចឹង?

ហ៊ុយ ខ្ញុំអត់ដឹង! ដឹងគេដាក់ថាម៉េចគេ ខ្ញុំអត់ដឹងដែរ ។

វណ្ណៈ ហើដល់ពេលណឹងមានប្រធាន មានមេគេឬនៅក្នុងកងពិសេស?

ហ៊ុយ មានរបស់គេទាំងអស់យូហើយ ។

វណ្ណៈ ពីណាគេមេគេ?

ហ៊ុយ តាណាគណឹង ។

វណ្ណៈ តាណាគណឹងពិសេសណឹងហ្នឹង? ចឹង៧០៣ នៅក្នុងភូមិភាគពិសេស?

ហ៊ុយ បាទ!

វណ្ណៈ ភូមិភាគពិសេសណឹងនៅតំបន់ណាខ្លះដែលនៅ...?

ហ៊ុយ នៅតាមទន្លេ...នៅតំបន់២៥ណឹងផងតាមតំបន់៣៣ផង ។

វណ្ណៈ ៣៣តំបន់ណាខ្លះ ៣៣? ហើយ២៥កន្លែងណាដែលចាត់ទុក២៥ ហើយកន្លែងណាគេហៅ

តំបន់៣៣?

ហ៊ុយ ទេ! ខ្ញុំមិនដឹងច្បាស់ដែរ...អា៣០...ច្រក...ជួនកាល៣៣ម៉ោងលស៊ីននេះ...ហឹទៅលើណោះ ៣៣មិនដឹងយកដីត្រឹមមាណយកទឹកដីត្រឹមមាណ ធ្វើព្រំប្រទល់ត្រឹមមាណៗអី ខ្ញុំអត់ស្គាល់ដែរណឹង ។

វណ្ណៈ បន្ទាប់ម៉ោពូទៅរៀនបច្ចេកទេសនយោបាយទៀត? ពូមុនពូរៀនម្តងហើយម៉េចបានគេឲ្យពូរៀនបន្ថែមទៀតចឹង?

ហ៊ុយ គាចូលអង្គភាពកងទ័ពគេណឹងគេឲ្យរៀនទៀតហើយ រៀនទាំងអស់គ្នាណឹងទាំងកង១ហ្នឹង ។

វណ្ណៈ ពេលរៀនណឹងពីណាអ្នកបង្រៀនពូ?

ហ៊ុយ ពេលបង្រៀនណឹងមានតែកងវរៈទេអ្នកបង្រៀន ។

វណ្ណៈ អ្នកណាគេកងវរៈណឹង?

ហ៊ុយ ខ្ញុំភ្លេចទៀតហើយយូរឆ្នាំហើយ ។

វណ្ណៈ ប្រធានគេហ្នឹងពូ?

ហ៊ុយ ទាំងប្រធាន ទាំងបញ្ជាការទាំងអីគេណឹង ។

វណ្ណៈ បង្រៀនណឹងសិតតាមនុស្សម៉ោពីណា?

ហ៊ុយ អង្គភាពណឹង ។

វណ្ណៈ ក្នុងអង្គភាពណឹង អត់មានក្រៅពី ផ្សេងពីណឹងទៀតទេ?

ហ៊ុយ បាទ! អត់មានទេ ។

វណ្ណៈ ហើយពូ បញ្ជូន ក្រោយម៉ោគេបញ្ជូនពូទៅវៃនៅផ្លូជាតិលេខ២នៅក្នុងឆ្នាំណាដែរហើយវៃជាមួយខាងណាដែរ?

ហ៊ុយ ឆ្នាំ៧៨ណឹង វៃជាមួយកងទ័ព លន់ ណុល ។

វណ្ណៈ កាលណឹងគេ...ម៉េចបានគេវៃគ្នាចឹងពូ?

ហ៊ុយ ដឹងអី! បើគេឲ្យទៅវៃគ្នាចឹងហើយ ។

វណ្ណៈ ពេលពូឡើងវៃគេប្រាប់ថាយ៉ាងម៉េចដែរ?

ហ៊ុយ ពេលវៃណឹង គេឲ្យយើងស្ងាត់ស្ងៀមនៅពេលចូលសមរភូមិ ។ ប៉ុនទៅគ្នា អាគ្នាចឹងណោះលើផងយំផងចង់ស្លាប់ ចុះខ្ញុំដែលអីខ្ញុំ ស្តាយកាំភ្លើងផងលីអាគ្នា៤-៥សន្ទឹក ហើយគេដើរ

គេដើរទៅបាត់អត់នៅតាតាមក្រោយគេ ។ ប៉ុនបានគ្នា២-៣នាក់តាមក្រោយសិតតាអ្នកអន់ជាងគេណាស់ លីយំផងអីផង ។ អ៊ូ! បើនឹកឃើញថាកុំតឹងតែងវិញអត់ទៅទេត្រឹមមាណដេកត្រឹមណឹងហើយ ប៉ុនគេតឹងតែង បើកាលណាយើងទៅមិនទាន់គេក៏គេវិន័យយើងដែរបាទ! ។

វណ្ណៈ ហើពូរៃនៅកន្លែងណឹងនៅឆ្នាំណា ហើយអស់រយៈពេលប៉ុន្មានដែរ?

ហ៊ុយ ភ្លេចអស់ហើយ! មិនដឹងរយៈពេលប៉ុន្មាន ។

វណ្ណៈ ហើពូមានបានឡើងរៃជាមួយគេទេណឹងដែរ?

ហ៊ុយ ទៅជីកត្រង់សេ គេឲ្យនៅត្រង់សេ១គ្នា៣នាក់ ត្រង់សេ១គ្នា៣នាក់ ។

វណ្ណៈ ហើរៃរយៈពេលប៉ុន្មានដែរនៅសមរភូមិលេខ២ណឹង?

ហ៊ុយ ទេ! មិនដឹងប៉ុន្មាន ភ្លេចអស់ហើយ ។

វណ្ណៈ ហើចុះនៅសមរភូមិបាទីវិញ?

ហ៊ុយ គេបញ្ជូនទៅ បញ្ជូនម៉ោ១ណឹង ជួនកាលគេឲ្យម៉ោនៅណេះ នៅត្រឹមព្រៃស្វានេះ ជួនកាលគេបញ្ជូនចេញពីណឹងឲ្យទៅនៅទន្លេបាទីគេខ្លាចយន្តហោះទម្លាក់ណាស់ ។

វណ្ណៈ កាលណឹងយន្តហោះដែលទម្លាក់ម៉ោដែរ?

ហ៊ុយ បាទ! យន្តហោះទម្លាក់ ។

វណ្ណៈ យន្តហោះរបស់ពីណាគេណឹង?

ហ៊ុយ យន្តហោះពីភ្នំពេញម៉ោ ។

វណ្ណៈ របស់ពីភ្នំពេញណឹងរបស់...?

ហ៊ុយ របស់លន់ ណុល ។

វណ្ណៈ យន្តហោះណឹងរាងយ៉ាងម៉េចដែរ?

ហ៊ុយ យន្តហោះស្លាបកាត់ ហើយន្តហោះធុនម៉ិច អាម៉ិចកំភ្លិចកំភ្លាក់ណឹង អាស្លាបកញ្ច្រឹបណឹង ។ ដឹងម៉ាកអីបើខ្ញុំមិនស្គាល់ផង ។

វណ្ណៈ ហើទាហានពូដែលរងការទម្លាក់ពីយន្តហោះណឹងដែរ?

ហ៊ុយ បាទ! យន្តហោះអាម៉ិចណឹងទម្លាក់ងាប់អស់គ្នាប៉ុន្មាននាក់ណោះ ក្នុងសមរភូមិណឹង ។

វណ្ណៈ ពូ! ខ្ញុំចង់ឲ្យពូនិយាយពីសកម្មភាព ពី...ពូឡើងវៃសមរភូមិមួយៗ ហីការទុបទល់គ្នាកម្លាំង ទៅវិញទៅម៉ោណឹងដែលពូនៅចាំណាស់ សុំពូនិយាយមើល៉?

ហ៊ុយ ពេលវៃជាមួយគ្នា... ជាមួយទាហានណឹងយប់... ចុះយប់វៃ ដល់នេះបញ្ជាការគេដើរប្រាប់ ប្រាប់ថាទិចទៀតផ្ទុះកាំភ្លើងហើយ ប្រយ័ត្នបន្តិចកុំទៅណា ៗហីគ្មានអ្នកណាហ៊ានដើរទៅណានៅតាក្បែរត្រង់សេ តាផ្ទុះអាចម៍ណឹងក៏ក្បែរត្រង់សេដែរ មិនហ៊ានទៅផ្ទុះអាចម៍ដល់ណាឆ្ងាយទេ ៗ ដល់ពេលបាញ់គ្នាឥឡូវគេថាផ្ទុះអាវុធហើយ គេបាញ់មុនបញ្ជាការគេបាញ់ស៊ីញ៉ូឲ្យទៅ ផ្ទុះអាវុធប្រាវទៅ ហីយើង ចុះយប់ទៅមើលឃើញអាណាបេះតាបាញ់ទៅ បេះតានាំគ្នាបាញ់ទៅអាងិតឈើង បាញ់ទៅបាញ់ម៉ោៗៗណឹងទៅ ៗ ខ្ញុំបាញ់មិនឃើញទាហានដឹងបន្ទាយនៅចំណាហង បេះតាបាញ់ទៅ ៗ

វណ្ណៈ ពេលណឹង ក្នុងពេលធ្វើសង្គ្រាមណឹង សព្វាវុធ អាវុធហើយនិងការឧបត្ថមផ្សេងៗណឹងបានម៉ោពីខាងណាដែរ?

ហ៊ុយ អាវុធសិតតាកាំភ្លើងចាស់ បាទ! កាំភ្លើងចាស់ៗ ដូចយ៉ាងកាំភ្លើងរបស់ខ្ញុំអាសេកាសេ ១០គ្រាប់ណឹង កាំភ្លើងសោតឹងមិនជាប់ផង ៗ ហីដល់ក្រោយម៉ោវាមានអាវុធថ្មីគេ ប៉ុនអាណឹងគេអត់បើកឲ្យទាហានទឹមនេះទេណាស់ គេទុកតាសម្រាប់ទាហានគេចាស់ៗហ្នឹង ៗ

វណ្ណៈ ទាំងអាវុធចាស់ទាំងអាវុធថ្មីណឹងច្រើនបានម៉ោពីខាងណាពូ?

ហ៊ុយ មិនដឹងដែរ ៗ

វណ្ណៈ ប៉ុនអាវុធថ្មីណឹងច្រើនមានម៉ាកដែរ?

ហ៊ុយ អាវុធថ្មីមានម៉ាក! មានម៉ាករបស់សូវៀតផង មានម៉ាករបស់ចិនផង ៗ

វណ្ណៈ របស់សូវៀតម៉ាកអីរបស់ចិនម៉ាកអីដែរពូ?

ហ៊ុយ អ្ហឺ! ដឹងម៉ាកអីទេ មិនស្គាល់ម៉ាកវាផង ៗ ប៉ុនគ្រាន់ថាអាណាអត់មានអាកាប៉ឺគេនោះ មានអាកាប៉ឺដាក់លាតដោយខ្លួន អាកាប៉ឺដាក់ចង្កេះគេណឹង អាណឹងរបស់សូវៀត ហីអាណាមានកាប៉ឺជាប់ណឹងកាណុងណឹង អាណឹងរបស់ចិន ៗ ប៉ុនមិនដឹងកាំភ្លើណារបស់អាណា បើអក្សរដូចតាគ្នា អក្សរចិន បើអក្សរដូចអក្សរចិនចឹង ៗ

វណ្ណៈ អាណឹងគេ... ពូចាប់ឃើញមានអាវុធថ្មីៗណឹងនៅឆ្នាំណាដែរពូ?

ហ៊ុយ ឆ្នាំ៧៤ ៗ

វណ្ណៈ បន្ទាប់ម៉ោគេបញ្ជូនពូទៅបឹង៥០០ណឹងទៅធ្វើអីទៀតពូ? ហ៊ីទៅស្ពានភ្នំបន្តទៀតណាស់?

ហ៊ុយ បាទ! អាណឹងនៅទាហានណឹងគេសម្រាប់ឲ្យ...គេផ្លាស់ៗកន្លែងណឹងដើម្បីដកយកទៅវៃទៀត ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីសមរភូមិនៅបឹង៥០០ នៅស្ពានភ្នំ ហ៊ីនៅអ្នកគាយ៉ាំងមៀងអី នៅទន្លេអីលម្អិតណាស់ និយាយពីសកម្មភាពនៅក្នុងណឹងមួយទៀត?

ហ៊ុយ វៃគ្នាដូចតែគ្នាណឹង!

វណ្ណៈ វៃរហូត?

ហ៊ុយ បាទ!

វណ្ណៈ ពេលដែលពូឡើងទៅសមរភូមិមួយៗណឹងពូ ពេលវៃគ្នាម្ដងៗ និយាយពីស្ថានភាពរបួស និយាយពីពេលដែលពូវៃទៅលើខ្មាំង វៃទៅលើភាគីម្ខាងទៀតណឹងពូមានឃើញអ៊ីដែលប្លែក អ៊ីដែលចម្លែក ដែលពូចាប់អារម្មណ៍ដែរ?

ហ៊ុយ វៃទៅទាហានគេក៏មិនដែលឃើញគេរបួស មិនដែលឃើញគេនេះដង ។ ប៉ុនតាឃើញតាខាងឯងនេះ ខាងទាហានខាងនេះវាងាប់របួសសែងបន្តរហូត ។

វណ្ណៈ ខ្ញុំចង់សួរពូ ជាគំនិតរបស់ពូយល់ឃើញថាយ៉ាងម៉េចពេលដែលពូធ្វើសង្គ្រាមណឹង ហើយនិយាយពីបទពិសោធន៍របស់ទាហាននៅក្នុងកងរបស់ពូក្នុងពេលធ្វើសង្គ្រាមណាស់ វាមានបទពិសោធន៍យ៉ាងម៉េចដែរ អាណឹងគុណភាពវៃណឹងយ៉ាងម៉េចដែរ?

ហ៊ុយ បទពិសោធន៍ណឹង... ម្នាក់ៗវាគ្មានអ្នកណាមានបទពិសោធន៍ជាងអ្នកណាទេ បើអ្នកបាក់ស្មារតីដូចពួកខ្ញុំអីអ៊ីនអ្នកដែលថាខ្លាចស្លាប់ខ្លាចអី គ្មានអ្នកនៅណាចង់ច្បាំងទេ ប៉ុន្តែច្បាប់វាវាគឺងតែងពេក បាទ! ។ តាម៉ោក្រោយត្រូវតាគ្រោះថ្នាក់ ហ៊ីបើនៅណឹងចេះតានៅទៅ ។ ចុះដល់យូរៗទៅធម្មតា ថ្ងៃណាងាប់ៗទៅ បើម៉ោផ្ទះរត់ម៉ោផ្ទះក៏មិនបាន បាទ! រត់ម៉ោផ្ទះគឺជាប់គុក ងាប់! ហ៊ីបើនៅណោះគេឲ្យបាយស៊ីធម្មតាជាទាហានចឹង ហ៊ីច្បាំងបើថាងាប់គ្រាប់បាញ់ត្រូវយើងងាប់ទៅ ផ្លោងម៉ោត្រូវងាប់ទៅ អាណឹងវាធើម៉េចវាត្រូវតាចឹងហើយដល់ចឹងម្នាក់ៗតាគេឲ្យទៅនៅវៃកន្លែងណា ទៅវៃកន្លែងណឹង គេមិនឲ្យបានទៅក្រោយ... បានមើលមុខគ្នា ។ ប៉ុនទៅវៃម្ដងៗ បើមុនទៅវៃបណ្ដើរគ្នាទៅទាំងជួរមើលមុខគ្នាហើយ ។ មើលមុខគ្នាអាណឹងបើថាងាប់ អាណឹងវាបែកគ្នាហើយ បើថាមិនទាន់ងាប់អាណឹងម៉ោវិញ

គៀកកគ្នាហើយ ។ ហីពេលទៅជីកត្រង់សេរ៉ៃ២-៣អីចឹង គ្រប់សមរភូមិចឹង បើគេឲ្យយាមម្នាក់៣ម៉ោអីចឹងយើង...តាម“ពួក” យើងក្នុងម៉ាត្រង់សេយើងដាក់វេនគ្នាប៉ុន្មានម៉ោង ១នាក់ដល់ភ្លឺ យើងយាមទៅ ។ ៣ម៉ោងម្នាក់ ត្រូវ៣ម៉ោងម្នាក់ ៣ម៉ោងម្នាក់ ។ ហីបើថាអ្នកណាយាមងក់យាមអី អាណឹងពេលចេញពីសមរភូមិវិញ... គេឲ្យប្រជុំរៀនសូត្រ ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីកម្រិតវិន័យហើយនិងទោស ចំពោះទាហានណាស់ ឧបមាថាយើងរត់ពូនិយាយរត់ចោលជួរ យើងចង់ឡប់ម៉ោផ្ទះចឹងគេ ធ្វើទារុណកម្ម គេដាក់...គេធ្វើបាបយើងអាណឹងក្នុងកម្រិតណាខ្លះ គេធ្វើយ៉ាងម៉េចខ្លះចំពោះទាហានណឹង?

ហ៊ុយ កាលដំបូងដែលខ្ញុំ...ខ្ញុំនែ៎ រត់ម៉ោផ្ទះដំបូងបានប៉ុន្មានបាន៥ថ្ងៃទៅវិញ គ្រាន់តាកម្រិតរបស់គេ គេគ្រាន់ត្រឹមម៉ានិយាយប្រាប់ខ្ញុំទេណាស់ កាលមុនឲ្យ...អឺ កម្រិតប្រាប់ខ្ញុំទេ គេថាអ៊ីស៎! ហ៊ុយ ឯងប្រញាប់ម៉ោ អញថាឲ្យគេទៅទទួលដល់ផ្ទះតើ គេអញ្ជើញពីផ្ទះម៉ោវិញ ។ ខ្ញុំថា ខ្ញុំនឹកឃើញខ្លួនខ្ញុំ នឹកឃើញថាខ្ញុំបើពួកកុំម៉ោទាន់ បើពួកណឹងទៅតាមដល់ផ្ទះប្រហែលគេដាក់ខ្នោះពីផ្ទះម៉ោមែនណឹង ចងឯងពីផ្ទះម៉ោមែនណឹង បេះម៉ោទាន់ ។ ដល់ហើយគិតម៉េច...លែងទៅហើយ ។ ប៉ុនក្រោយនៅតាលួចម៉ោទៀត ឲ្យតាម៉ោដេកពេទ្យគឺខ្ញុំលួចម៉ោផ្ទះហើយ លួចម៉ោលេងផ្ទះជួនកាលសុំច្បាប់ពេទ្យទៅ ពេទ្យត្រូវគ្នាបានម៉ោលេងផ្ទះទៅពេទ្យអត់មានវិន័យ ។ ហីថា...អត់ត្រូវជាមួយពេទ្យលួចលាក់ម៉ោ ប៉ុនលួចលាក់មានម៉ោងម៉ោ២-៣ម៉ោចឹងទៅ ម៉ោខ្ទិកង់ខ្ទិអីគេជិះម៉ោ មើលម៉ែឪម៉ាភ្លេតទៅវិញ ។ អត់ហ៊ាននៅយូរទេ ព្រោះខ្លាចតា ពេទ្យដឹងពេទ្យរាយការណ៍ទៅត្រូវគ្រោះថ្នាក់ទៀត ។ វិន័យរបស់ទាហានពេលដែលរៀនសូត្រ អាស់ពេលដែលខុស... គេថាខុសទី១គេកសាង ខុសទី២គឺគេលែងដឹងលែងព្រហើយ ។

វណ្ណៈ ខ្ញុំចង់សួរពីអារម្មណ៍របស់ពូ ពេលដែលពូនៅដេកពេទ្យ ហើយពូត្រឡប់ម៉ោផ្ទះតា១ម៉ោង ២ម៉ោងណឹង អារម្មណ៍របស់ពូដែលម៉ោផ្ទះ១ម៉ោង ២ម៉ោងណឹងវាយ៉ាងម៉េច ហើយបើសិនជា...?

ហ៊ុយ អាម្មណ៍ម៉ោផ្ទះខ្ញុំ ម៉ោផ្ទះខ្ញុំអាល័យម៉ែឪខ្ញុំ អត់ចង់ទៅវិញទេ បាទ! ។ បានថាអត់ចង់ទៅវិញច្បាំងគ្នាដឹងស្លាប់ថ្ងៃណា ហីមួយទៀតអាល័យម៉ែអាល័យឪ ។ គ្រាន់ឪពុកខ្ញុំគាត់ទៅជួបជាមួយខ្ញុំម្តង មែននេះទេខ្ញុំអាល័យម៉ែឪណាស់ ប៉ុនកង្វរៈនៅណឹង អាស់នែ៎ មេក្រុមនៅ

ណឹងខ្ញុំអត់ហ៊ានថា... ថាអ៊ីចុះម៉ោធើអី? នៅចម្ងាយណាណីហីម៉ោ ។ ហីគាត់ចាស់ហើយ គាត់ជិះកង់ទៅរកខ្ញុំណាស់ រ៉ិចនំអន្សមអីយកទៅណាស់ ប៉ុនឃើញនំអន្សមឆ្អែតហើយ វា អាល័យម៉ែឪពេក ។ ដល់គាហើយម៉ោ ខ្ញុំថាចឹង១ កង... អាស៎ មេក្រុមខ្ញុំក៏គាត់ស្តីឲ្យខ្ញុំ ថា"យីអ្ហែងនិយាយចឹង! ម៉ែឪអាល័យណាស់ គាត់កាត់ម៉ោរកកូន..." ដល់នឹកឃើញចឹង អ៊ីស៎! មេក្រុមគ្រាន់បើ! បេះនឹកឃើញចឹង! ។ ប៉ុនតែខ្លួនឯងនេះអាល័យម៉ែឪចង់ងាប់ ហើយ ប៉ុនបើមិនថាចឹងគេ កុំឲ្យអាមេក្រុម កុំឲ្យគេអ្នកធំគេចោទយើង ម្លោះហើយខ្ញុំ... "អ៊ីស! ប៉ា(ឪពុក)ខ្ញុំអាល័យចង់ងាប់ហើយទៅណារួច សុំគេអត់ហ៊ានសុំ យើងសិតតាទ័ព ទើបបញ្ជូនម៉ោចឹង សុំគេទៅ... គេអត់ឲ្យទៅផ្ទះទេ គេខ្លាចយើងរត់" ដល់ហើយបេះតា ប្រាប់គាត់... បេះតាប្រាប់គាត់ថា "ខ្ញុំដឹងថ្ងៃណាទៅណាទៅណីទៀតទេ ឈប់ម៉ោឈប់អី ទៅ ព្រោះពេលបញ្ជូនម្តង១ក៏មិនដឹងគេបញ្ជូនទៅណាអីណាដែរ គេអត់ដឹងគេអត់ប្រាប់ យើងទេ បាទ!" ។ គាត់ថា"នៅកន្លែងណាក៏ដោយបើឃើញមានណាអ្នកស្គាល់គេនៅជិតផ្ទះ នៅជិតអី ផ្តាំ១គេទៅ អញ...ម៉ោលេងណឹង..." ។ គាត់កាត់ទៅរកដល់សមរភូមិដល់អី ណោះទៀត ប៉ុន្មានយប់ ប៉ុន្មានថ្ងៃណោះរងគ្រាប់ផ្លោង គ្រាប់អីណោះទៀត នឹកឃើញថា ម៉ែឪអាល័យកូន ចុះបើទទួលគ្រាប់ផ្លោងបើគ្រោះថ្នាក់គាត់ ខ្ញុំក៏មិនដឹងថាម៉ែឪខ្ញុំទៅរកខ្ញុំដែរ បានថារឿងម្នាក់១ខ្ញុំចាត់ទុកថាចឹង អ្នកណាមិនអាល័យផ្ទះ មិនអាល័យសម្បែង មិនអា ល័យម៉ែឪ មិនចង់ធើអាសន្រ្កាមទេ ។ ប៉ុនតែអាគេណោះ គេបេះតាបញ្ជូនយើងយកទៅ ហើយមិនឲ្យម៉ោផ្ទះសម្បែងវិញ ។ អើ បើដូចច្បាប់អាឡូវវិញ ងាប់ហើយខ្ញុំមិនបានទៅធ្វើ ទ័ពទេ! ច្បាប់អាឡូវមានប្រាក់ខែស៊ីហើយបើយើង...ឈប់ក៏ឈប់ទៅ ។ ច្បាប់កាលនោះ អត់បានទេ តាយើងរត់ចោលជួរណឹងត្រូវតាមានវិន័យមានទោសកំហុសរបស់យើងហ្នង ។

វណ្ណៈ វិន័យណឹងពីណាអ្នកដាក់ម៉ោ បញ្ជាឲ្យមាន...?

ហ៊ុយ ខ្ញុំមិនដឹងវិន័យចេញពីណាម៉ោ ប៉ុនតាខុសកងវរៈកងវរយណឹងគេអ្នកវិន័យយើងណឹងហ្នង ព្រោះគេជាមេណឹង ។

វណ្ណៈ ហីក្នុងការដាក់វិន័យណឹងពូមានដែលឃើញមានចំពោះពូ ឬក៏មនុស្សផ្សេងទៀត មានឃើញ កើតមានអីជា...?

ហ៊ុយ បាទ! ខ្ញុំឃើញមួយហើយ នៅកងជាមួយខ្ញុំ រត់ម៉ោផ្ទះ ។ រត់ម៉ោផ្ទះទទួលថ្ងៃណឹង...គេដក

ពួកខ្ញុំណឹងម៉ោឲ្យរៀន កងគេហៅកងសម្រុកគេនោះ បាទ! គេហៅកងសម្រុកគេនោះ ។ ខ្ញុំម៉ោរៀនកន្លែងណឹង កន្លែងព្រៃកគួចនេះខ្ញុំនិយាយលាក់បាំងអីកន្លែងព្រៃកគួច ឃើញអាក្នុងចាយដី ទៅមើល ហាត់ៗស្រាប់តា អាគ្នាខ្ញុំណឹងវាប្រាប់ណាស់ "ណាក់អ្ហែងមើល៎ អានេះនៅក្នុងចាយដីណោះ ជាប់ច្រវ៉ាក់នៅជើង ហីខ្ញាំ១ដាក់បាយឲ្យស៊ី" ។ ខ្ញុំហាត់ៗ ខ្ញុំទៅហាត់ចំអាមុខចាយដីណឹង ។ ដល់ហើយខ្ញុំលួចមើលទៅ ចុយម្ដាយហើយអ្ហើយ ឃើញអាណិតគេហើយណាស់ ។ ចុះ...ដឹងធើម៉េចទេ បើខ្លាចក៏ខ្លាចដូចតាគ្នា អ្នកណាក៏ខ្លាចដែរ ។ បើម្នាក់នោះវិញមាឌដូច គាត់ចឹង(នាន) គ្នាទឹមទៅបានប៉ុន្មានថ្ងៃ រើសយកចូលកងពួកខ្ញុំណឹង ដល់ហើយទៅវៃ វៃកាលណឹងវៃនៅតាមផ្លូវជាតិលេខ២ណឹង និយាយពីញាក់ ញាក់ឲ្យឡើងសើមខ្លួនជោកទៅណាស់ សិតតាទឹកទាំងអស់ ញាក់ដល់ថ្នាក់គ្មាចងសន្ទប់ ចុះបាញ់គ្នា គ្នាដែលធ្លាប់បាញ់អី ។ ដល់ហើយគាត់ថា "អ៊ីស៎! ខ្ញុំ... ខ្ញុំលែងនៅហើយៗ" ខ្ញុំថា" អ៊ីស៎! លែងនៅម៉េច វិន័យគេអត់បានទេណាស់ លែងនៅ... បើថាគេបាញ់បាញ់ទៅ លើកតាកាំភ្លើងបាញ់ទៅ អោនក្បាលទៅក្រោយត្រង់សេទៅ ហីម៉េចៗគ្រាប់ផ្ទាំងរួតតាក្រាបទៅ" ។ ហីខ្ញុំដល់ឃើញអាគេដាក់ទណ្ឌកម្មនៅក្នុងចាយដីណឹងចឹង ខ្ញុំខ្លាច! ខ្លាចគេដាក់ទណ្ឌកម្មចឹងដែរ បានបេះតានៅៗនឹងគេទៅ ។

វណ្ណៈ ពូម្នាក់ណឹងឈ្មោះអីដែរពូ?

ហ៊ុយ ទេ! ដឹងឈ្មោះអីទេកាលណឹង ព្រោះវាយូឆ្នាំហើយតាំងពីដកម៉ោ ហីរៀន រៀនហើយមិនឃើញម្នាក់ណឹងទៀត លែងទៀត គេលែងឲ្យចូលម៉ោរៀនសូត្រណឹងទៀតទៅ រៀនបច្ចេកទេសណឹងណាស់ ។

វណ្ណៈ ពេលដែលពូឃើញណឹង ម្នាក់ណឹងនៅមានស្ថានភាពយ៉ាងម៉េចដែរ ស្លាប់ ឬ រស់?

ហ៊ុយ រស់! នៅរស់ ។ ប៉ុន្តែអាឡូវនេះអត់ដឹងទេ ដឹងនៅណាអីណាទេ ។

វណ្ណៈ ប៉ុនពេលដែលពូឃើញណាស់?

ហ៊ុយ បាទ! ឃើញនៅជាប់នៅក្នុងណឹង ណឹងគេរត់ម៉ោផ្ទះណឹងណាស់ ។

វណ្ណៈ អាណឹងពូឃើញផ្ទាល់ភ្នែកហ្មង?

ហ៊ុយ បាទ!

វណ្ណៈ នៅណឹងមានគេបែកចែកជាកងសម្រុក ជាកងពិសេស ។ កងសម្រុកណឹងមានន័យថាម៉េច

ហើយកង...?

ហ៊ុយ កងសម្រុកណឹងគេដាក់ជាកងពិសេស បាទ! កាលមុនគេអត់មានហៅកងពិសេសទេ ។កាលមុនកងពិសេសរបស់គេមាន ប៉ុនដល់តាវៃយូរៗទៅវាអាលាយអស់ទៅ ឆាប់ចង់អស់ទៅ បានគេលែងដាក់ឈ្មោះកងណឹងគេ រំលាយចោល ។ ដល់ក្រោយម៉ោមិនដឹងយ៉ាងម៉េចគេរើសទៀត គេរើសកងណឹងទៀត បានគេលែងដាក់ឈ្មោះថាកងពិសេសគេហៅថាកងសម្រុកវិញ ។

វណ្ណៈ ក្នុងម៉ាកងណឹងមានគ្នាប៉ុន្មាននាក់ដែរពូ?

ហ៊ុយ ម៉ាកងណឹងមានគ្នាប៉ុន្មានទេ ៤០ អីណឹង ។

វណ្ណៈ អាណឹងមានលេខដែរពូ?

ហ៊ុយ ទេ លេខកាលណឹង... អត់មានទេគេដាក់ឈ្មោះកងសម្រុកចឹងហ្នង ។

វណ្ណៈ ហើយកាលណឹងពីណាគេក្តាប់កងសម្រុកណឹង ឈ្មោះអីដែរ?

ហ៊ុយ ក្តាប់កងសម្រុកណឹងកាលមុន... កាលមុនពួកបង**ហ៊ុយ** បងហ៊ុយ**សមាជិក**មន្ទីរ ណឹង **មន្ទីរស-២១**ណឹង ។

វណ្ណៈ គាត់ណឹងប្រធាននៅកងសម្រុកណឹងហ្នង ហ៊ុយ?

ហ៊ុយ បាទ!

វណ្ណៈ មានទីតាំងហើយធ្វើសកម្មភាពគេនៅម្តុំណាពូ?

ហ៊ុយ អត់មានទីតាំងទេ នៅដូចទ័ពចឹងនៅដូចតែគ្នា ដើរនៅតាមផ្ទះតាមអីដូចតែគ្នាណឹងចង់កងពលគេដកឲ្យទៅវៃណាឲ្យអី គេបញ្ជូនទៅហ្នង ។

វណ្ណៈ អាណឹងស្ថិតនៅក្រោយកងពល បញ្ជាករកងពលដែរ?

ហ៊ុយ បាទ!

វណ្ណៈ ហីពេលដែលពូក្នុងកងទ័ពណឹងគេឲ្យយើងរបបហូបចុកណឹង សម្លៀកយ៉ាងម៉េចដែរ?

ហ៊ុយ សម្លៀកបំពាក់ខោអាវតាប៉ុន្មានកំប្លេដូចគ្នាណឹង ពាកំប្លេៗណឹង ។ ប៉ុនគ្រាន់ថាវាបានប៉ុណ្ណេះបានថា ពេលរៀបទៅច្បាំងគេឲ្យទៅវៃណឹងគេឲ្យ កាប់ជ្រូកកាប់គោអីមួយចឹងទៅសម្រាប់ពួកកងណឹងស៊ីហើយដឹងតាដេក១ថ្ងៃណឹង ។ ដល់ពេលល្ងាចម៉ោ៣ ម៉ោង៤ណឹងគេបញ្ជូនទៅហើយ ។

វណ្ណៈ សម្លៀកបំពាក់៣-៤ណឹងគេឲ្យយ៉ាងម៉េចពូ?

ហ៊ុយ ខោរអាវសម្លៀកបំពាក់ធម្មតាជាទ័ពណឹង កាលណឹងខោរអាវខ្មៅណាស់ បាទ! ណឹងម្នាក់៣កំប្លេៗ ។

វណ្ណៈ ក្រណាត់ពណ៌ខ្មៅ?

ហ៊ុយ បាទ! ទាំងអស់ដូចទ័ព ដូចកងឈ្មើរជើងឈ្មើអីចឹង ។

វណ្ណៈ ខ្ញុំចង់សួរបញ្ជាក់កន្លែងនេះ នៅក្នុងកងណឹងវាមានគេបែងចែកជាកងសម្រុក កងឈ្មើរជើងអី កងពិសេសអីយ៉ាងម៉េចដែរពូ តាមលំដាប់កងពលម៉ោវាមានយ៉ាងម៉េចសាខាគេ មានប៉ុន្មានពូ?

ហ៊ុយ កងពិសេសអាណឹងនៅក្រោមការដឹកនាំរបស់កងពល ហីកងនេះណឹង កងឈ្មើរជើងណឹងនៅក្រោមការដឹកនាំរបស់កងវរៈសេនាធំ បានទៅកងពលណឹងដែរ ប៉ុនវានៅកងពលជាមួយជាមួយតែគ្នា ។

វណ្ណៈ ហីនៅក្នុងកង... ក្នុងវង្វង់កងទ័ពមួយ **កងពល៧០៣**មួយណឹងណាស់ វាមានបែងចែកទៅជាផ្នែកអ៊ីខ្លះនៅក្នុងវង្វង់ក្តាប់របស់កងពលណឹង?

ហ៊ុយ បាទ! អាណឹងខ្ញុំដឹងទេណាស់ ដឹងតា **ឈ្មើរជើង កងសម្រុក** ហី **ស៊ើបការណ៍ ហីកាំភ្លើងធំ** ។

វណ្ណៈ ឈ្មើជើងវាមានបែងចែកតទៅទៀតដែរ?

ហ៊ុយ អត់ដឹង! អត់មានបែងចែកអីទេ គ្រានតាទ័ពឈ្មើរជើងណឹងហ្នុង ។

វណ្ណៈ នៅណឹងគេបែងចែកជាវរៈ ជា...ស្អីៗ មានលេខ...?

ហ៊ុយ បាទ! ជាកង ជាកងវរៈ ជាអីណឹង មានលេខរបស់គេ បាទ! ហីអាកងសម្រុកនេះកាលមុនអត់មានលេខទេ មានលេខតា ទឹមម៉ោក្រោយទេ គេហៅ...ប៉ុន្មាន៧០៤អី ហៅប៉ុន្មានទេ ។

វណ្ណៈ មានលេខណឹងប្រហែលនៅឆ្នាំដែរពូ?

ហ៊ុយ អាណឹងឆ្នាំប៉ុន្មានហើយទេ មើស៎! ដឹងឆ្នាំប៉ុន្មានទេ ។

វណ្ណៈ នៅក្នុងកងពល៧០៣ទាំងមូលណឹងមានប៉ុន្មានវរៈ មានប៉ុន្មាន...?

ហ៊ុយ អត់ដឹងទេ! អត់ដឹងមានប៉ុន្មានកងវរៈទេ ។

វណ្ណៈ ហើយនៅក្នុង... ពូនៅក្នុងវរៈ១២ហ្នឹង ជាវរៈសេនាធំឬជាវរៈសេនាតូច?

ហ៊ុយ វរៈសេនាតូច ។

វណ្ណៈ វរៈសេនាតូចទេ?

ហ៊ុយ បាទ!

វណ្ណៈ ហើយស្ថិតនៅក្នុងវរៈសេនាធំលេខប៉ុន្មានដែរ?

ហ៊ុយ យី! ដឹងវរៈសេនាធំលេខប៉ុន្មានហើយ ។

វណ្ណៈ ហើយពូនៅក្នុងហ្នឹងមានតួនាទីអីដែរនៅក្នុង...?

ហ៊ុយ កាលហ្នឹងយុទ្ធជន ។

វណ្ណៈ យុទ្ធជន?

ហ៊ុយ បាទ!

វណ្ណៈ ពេលពូឡើងវៃនៅផ្លូវជាតិលេខ២១ ពូ...នៅឆ្នាំណាដែរ? ហើយវៃជាមួយអ្នកណាទៀត?

ហ៊ុយ អាហ្នឹង៧៤ ៧៥ វៃជាមួយខាងកងទ័ព លន់ ណុល ។

វណ្ណៈ ហើនៅឆ្នាំហ្នឹង ពេលវៃហ្នឹងពូមានដែលឃើញទាហានពីណាផ្សេងមក៉ជួយពូដែរ?

ហ៊ុយ អត់មាន ព្រោះកាលនឹងគេដាក់ជាខ្មែរគ្រៀមហ្នឹង បាទ! ។

វណ្ណៈ ហើក្រោយម៉ោពូវៃ ឈឺទៅដេកពេទ្យហ្នឹង ទៅដេកពេទ្យនៅឯណាដែរពូ?

ហ៊ុយ ពេទ្យនៅ... ចំមុខកោះខែលនេះខាងកើត គេហៅពេទ្យព្រែកជន់ ។ គេហៅពេទ្យព្រែកជន់ ហើយអាហ្នឹងពេទ្យ...។ ពេទ្យហ្នឹងក៏មិនដឹងជាពេទ្យរបស់តំបន់អីពេទ្យរបស់ភូមិភាគអីក៏ខ្ញុំមិនដឹង ប៉ុនអ្នកឈឺគេច្រើនគាបញ្ជូនមកកន្លែងហ្នឹង ។

វណ្ណៈ អាហ្នឹងពេទ្យសម្រាប់ប្រជាជនឬក៏ពេទ្យសម្រាប់កងទ័ព?

ហ៊ុយ ពេទ្យសម្រាប់កងទ័ព ។

វណ្ណៈ ប្រជាជនមានសិទ្ធទៅបានទេ?

ហ៊ុយ អត់ទេ!

វណ្ណៈ នៅក្នុងពេទ្យហ្នឹង...គេផ្តល់សម្ភារៈពេទ្យហ្នឹង...?

ហ៊ុយ មានតាហូបបាយហូបអីហ្នឹង មានតាបាយទឹកទេ ។

វណ្ណៈ គេព្យាបាលមានថ្នាំសង្កូវគេ...?

ហ៊ុយ បាទ! ថ្នាំសន្លប់គេមាន ។

វណ្ណៈ ថ្នាំហ្នឹងពូមានដឹងថាថ្នាំម៉ោពីខាងណាដែរ?

ហ៊ុយ មិនដឹង! មិនដឹង! ដឹងថ្នាំខាងណា បើប្រាប់គេថាឈឺក្បាល គេឲ្យថ្នាំឈឺក្បាលម៉ោ ។

វណ្ណៈ គេថែរក្សាពូយ៉ាងម៉េចដែរនៅហ្នឹង ពូយល់ឃើញថាពេទ្យ ស្ថានភាពពេទ្យនៅពេលហ្នឹង?

ហ៊ុយ គ្មានថែរក្សាអីផងមានតែ... ឲ្យថ្នាំឲ្យអីហ្នឹង ហើយឈឺធ្ងន់គេត្រូវចាក់ ចាក់ទៅ ។

វណ្ណៈ ពេលដែលពូរត់ម៉ោផ្ទះប្រធានភូមិគេសួរហ្នឹង ប្រធានភូមិឈ្មោះអី ហើយយ៉ាងម៉េចបានជាគេម៉ោសួរពូអញ្ចឹង?

ហ៊ុយ គេប្រធានភូមិគេខ្លាចយើងរត់ម៉ោផ្ទះ ។ **ប្រធានភូមិ**ឈ្មោះណៃ **ឈ្មោះឆេង** ។

វណ្ណៈ អាហ្នឹងនៅក្នុងភូមិអីដែរពូ ភូមិ ឃុំ?

ហ៊ុយ នៅភូមិ កាលមុនគេហៅភូមិក្បាលជ្រោយ ហីដល់ម៉ាពួកខ្ញុំទៅបាត់អស់នេះគេដាក់ហៅភូមិលេខ៣ ឃុំពោធិបាន ស្រុកកោះធំហ្នឹងដែរ ។

វណ្ណៈ ប្រធានភូមិហ្នឹងជាប្រធានភូមិគេបង្កើតឥឡូវ ឬប្រធានភូមិគេចាស់គេម៉ោពីយូរយាម៉ោ?

ហ៊ុយ អាឡូវនេះ?

វណ្ណៈ និយាយពីប្រធានភូមិគេនោះ?

ហ៊ុយ កាលណោះប្រធានភូមិគេបង្កើតកាល ពីឆ្នាំ៧០ ប៉ុន្មានហ្នឹងម៉ោ...៧២-៧៣ ។

វណ្ណៈ កាលហ្នឹងនៅហ្នឹងគេហៅតំបន់អីដែរនៅហ្នឹង?

ហ៊ុយ ហ្នឹងតំបន់២៥ ហ្នឹងហ្មង ។

វណ្ណៈ គេបង្កើត... ខ្មែរក្រហមតែងតាំងថ្មីម៉ោហ្មង ឬក៏យ៉ាងម៉េច?

ហ៊ុយ អត់!

វណ្ណៈ មានចាស់ម៉ោហ្មង?

ហ៊ុយ ខ្មែរក្រហមអត់មានចេញពីហ្នឹងម៉ោផង ម៉ោពីលិចណោះវិញ ។

វណ្ណៈ ម៉ោពីខាងណាវិញ?

ហ៊ុយ ម៉ោពីខាង... តំបន់៣៣ ។

វណ្ណៈ ម៉េចបានពូដឹងថាខ្មែរក្រហមចេញម៉ោពីតំបន់៣៣ម៉ោ?

ហ៊ុយ ចុះបើ ចាស់វិនឃើញមៅតាពីលិច បើទ័ពវិញម៉ោតាំងជួរ មិនដឹងអ្នកណា គេអ្នកស្ម័គ្រចិត្ត

គេទៅធ្វើណឹងណាស់ គេរត់ចេញពីភូមិទៅបាត់អស់ហើយ គេទៅធ្វើទំពណឹង ។

វណ្ណៈ នៅខាងលិចទៅវិញ?

ហ៊ុយ បាទ!

វណ្ណៈ ខាងលិចណឹងតំបន់ណាពូ?

ហ៊ុយ តំបន់៣៣ ហីឃើញខោរខ្មៅអាវខ្មៅគេណឹង ដល់តាយូរៗ វាដល់អាពេលជ្រើសរើសតាមភូមិកំណែន ប៉ះចំពួកអ្នកអាយុត្រូវគេកេណ្ឌណឹងហ្នឹង ។

វណ្ណៈ កំណែនដាទូទៅណឹងគេយកពីអាយុប៉ុន្មានទៅពូ?

ហ៊ុយ ១៧-១៨ឆ្នាំ ។

វណ្ណៈ ហីក្រោយម៉ោគេបញ្ជូនពូទៅរៀននៅសាលាសេរី នៅ... ម៉េចបានគេបញ្ជូនទៅសាលាសេរីចឹងពូ?

ហ៊ុយ ចុះបើ... ពេទ្យគេរាយការណ៍ទៅប្រាប់កងវរៈខ្ញុំ ចុះតាចេញពីពេទ្យគេមានសំបុត្រមួយៗហើយណាស់ ម្នាក់សំបុត្រមួយៗ ហីតាម៉ោដេកពេទ្យមានឈ្មោះគេកត់នៅនឹងពេទ្យ ណឹងហើយ ។គេកត់នៅនឹងពេទ្យណឹងមានដេកក្បែរៗគ្នាណឹង មានអាមេក្រុមក្នុងរោងពេទ្យណឹងទៀតណាស់ បាទ! ឲ្យមើលខុសត្រូវទៀត ខ្លាចយើងដើរទៅណាម៉ោណាទៀត ។ ហីដល់ខ្ញុំចេញទៅចឹងសំបុត្រ... ឲ្យតាអ្នកចេញពីពេទ្យទៅ គេមានសំបុត្រមានឈ្មោះណឹងហ្នឹង អ្នកណាដើរហើរយ៉ាងម៉េច សេរីយ៉ាងម៉េច ទៅណាម៉ោណាអីពេទ្យគេសរសេរឈ្មោះបញ្ជូនទៅតាមណឹង ។

វណ្ណៈ យ៉ាងម៉េចបានគេឲ្យឈ្មោះថាសាលារៀនសេរីចឹងពូ មានន័យថាយ៉ាងម៉េច?

ហ៊ុយ បាទ! គណៈសាលាបង្រៀនសេរីណឹងគេនិយាយចឹងហ្នឹង គេថាសាលានេះជាសាលាសេរីអ្នកដែលខុសវិន័យ ។

វណ្ណៈ ចឹងអ្នកសាលាសេរី មានន័យថាមិនមែនសាលាណឹងបើកសេរីឲ្យយើងទៅណាតាមចិត្តទេ?

ហ៊ុយ មិនមែនទេ សាលាគេហៅសាលាសេរីណឹង អ្នកដែលខុសវិន័យគេឲ្យទៅរៀនណឹងហ្នឹង ។

វណ្ណៈ ហើយសាលាណឹងនៅក្នុងភូមិ ឃុំ ស្រុកអីដែរពូបញ្ជាក់កន្លែងណឹង?

ហ៊ុយ ក្នុងស្រុកកោះធំដែរ ប៉ុនមិនដឹងហៅឃុំអី ប៉ុនអាណឹង **វត្តកណ្ដាលកោះ ទឹកវិល** ។

វណ្ណៈ ហើយក្រោយម៉ោពូ គេបញ្ជូនពូចូលខាងកងវរៈ វរៈលេខប៉ុន្មានទៀតពូ?

ហ៊ុយ  កន់វេរៈ មិនដឹងកន់វេរៈលេខប៉ុន្មានទេ អាកន់សម្រុកគេណឹង ។

វណ្ណៈ  ចឹងអាណឹងពូដកពី វេរៈ១១២ណឹង ទេវថវេរៈគេផ្សេង ឬក៏យ៉ាងម៉េច?

ហ៊ុយ  បាទ! នៅវេរៈជាមួយគ្នាណឹង នៅកងពលជាមួយគ្នាណឹង បាទ! ។

វណ្ណៈ  ក្រោយម៉ោពូទៅវៃនៅកោះអន្ទង់ចិន ទៅវៃនៅស្រែអំពិលអីណឹង ទៅវៃនៅឆ្នាំណា ហើយទៅវៃជាមួយខាងណាទៀត?

ហ៊ុយ  អាណឹងឆ្នាំ ដើមឆ្នាំ៧៩ វៃជាមួយខាងទាហានលន់ ណុល សហការណ៍គ្នាជាមួយទាហានបូព៌ា ។

វណ្ណៈ  ក្រៅពីបូព៌ា ពូមានសហការណ៍ជាមួយខាងណាទៀត?

ហ៊ុយ  អត់មានទេ ។

វណ្ណៈ  ខាងបូព៌ាណឹងជាទាហានរបស់ខាងណាដែរ?

ហ៊ុយ  ខាងបូព៌ាកទាហាន... ទេ! ខ្ញុំមិនដឹងទេកាលណឹង គេថា**"ខ្មែររំដោះ១"**ដូចតែគ្នា គេឲ្យសហការណ៍គ្នាទៅជាមួយគ្នាទៅ ទៅវៃជាមួយគ្នាណឹងម៉ាច្រកៗម្នាក់ ម៉ាមុខព្រួញម្នាក់ ។ ខាងបូព៌ាវៃខាងត្បូងអញ្ចេះម៉ាមុខទៅ ពួកខ្ញុំវៃពីចំហៀងខាងជើងណេះម៉ាមុខម៉ោ ។ ដល់វៃអាទាហានរត់អស់ អាទាហានធ្លាក់ទឹកអស់ វាលេងអាគ្នាឯងណឹងទៀតទៅ ចុះគេអូមានដូចគ្នា និយាយគ្នាស្តាប់អត់បានវៃគ្នាទៀត ។

វណ្ណៈ  ក្រោយម៉ោពូទៅវៃនៅទន្លេមេគង្គ ម៉េចបានគេបញ្ជូនទៅវៃនៅទន្លេមេគង្គចឹងពូ?

ហ៊ុយ  មិនដឹង បើគេបញ្ជូនទៅ ។

វណ្ណៈ  ទន្លេមេគង្គគេវៃណឹងមានស្អីខ្លះ នៅទន្លេមេគង្គណឹង?

ហ៊ុយ  ទាហានដឹកសម្ភារៈពីខាងវៀតណាមម៉ោ ឡើងភ្នំពេញ ហីទាហាននៅការពារអាទន្លេណឹងអាគាមបន្ទាយៗណឹង គេឲ្យទៅវៃអាគាមបន្ទាយណឹង ។

វណ្ណៈ  ដឹកសម្ភារៈណឹងទាហានខាងណាដឹកទៅ?

ហ៊ុយ  ខាងទាហានលន់ ណុល ។

វណ្ណៈ  សម្ភារៈណឹងមានស្អីខ្លះទៅពូ តាមពូដឹង?

ហ៊ុយ  មានសាំង មានអី ។

វណ្ណៈ  ក្រៅពីសាំងមានអីទៀត?

ហ៊ុយ មិនដឹង!

វណ្ណៈ ដឹកជាស្អីតាមទន្លេមេគង្គណឹង?

ហ៊ុយ ដឹកកប៉ាល់ធំ ៗ

វណ្ណៈ ទន្លេមេគង្គនៅម្តុំណា នៅក្នុងខេត្តអីដែរពូ?

ហ៊ុយ ទន្លេមេគង្គវាមាំចំហៀងម្នាក់ណាស់ ខាងភូមិភាគបូព៌ាម៉ាចំហៀង ខាងតំបន់២៥ណឹងមាំចំហៀង ៗ

វណ្ណៈ អាណឹងនៅឆ្នាំណាដែរពូ?

ហ៊ុយ ឆ្នាំ៧៥ហើយអាណឹង ៗ

វណ្ណៈ ហើពូបានវៃទ ទៅដល់ទន្លេមេគង្គណឹង?

ហ៊ុយ បាន! ០វណាបាញ់ដូចតាគ្នាណឹង ៗ

វណ្ណៈ បាញ់ជាមួយ...?

ហ៊ុយ ខាងទ័ពលន់ ណុល ៗ

វណ្ណៈ ហើពេលណឹងសង្គ្រាមនៅណឹង ស្ថានភាពសង្គ្រាមនៅណឹងយ៉ាងម៉េចដែរ?

ហ៊ុយ បាទ! កន្លែងណឹងវៃខ្លាំង ខ្លាំងរហូត ម៉ាកងវរយ ម៉ាកងសម្រុកណឹងចង់អស់គ្នា នៅសល់គ្នាតែប៉ុន្មាននាក់ របួសហើស្លាប់ លើកោះតាឈឹងហ្នឹង ៗនៅសល់គ្នាប៉ុន្មាននាក់ក្រៅពីណឹងងាប់ហើរបួស ៗ

វណ្ណៈ **កោះតាឈឹង**នៅស្រុកអីដែរពូ?

ហ៊ុយ កោះណឹងមិនដឹងនៅខាងខេត្តណា មិនដឹងនៅខាងខេត្តកណ្តាលនេះ ឬក៏នៅខាងបូព៌ានេះក៏មិនដឹង ៗ

វណ្ណៈ គេមានគោលការណ៍ ទិសដៅគេវៃយ៉ាងម៉េចដែរបានគេសម្រុកខ្លាំងនៅទន្លេមេគង្គណឹង?

ហ៊ុយ អត់ដឹង!ប៉ុនគេនិយាយថាវៃកាត់ផ្លូវកុំឲ្យដឹកសម្ភារៈឡើងភ្នំពេញ កាត់ផ្លូវអាណឹងជាប់ហើយវៃភ្នំពេញបាដោយ ៗ

វណ្ណៈ តាមពូយល់វិញទន្លេមេគង្គជាកន្លែងអីមួយរបស់លន់ ណុលណឹង?

ហ៊ុយ កន្លែងដឹកសម្ភារៈចូលទៅភ្នំពេញណឹង ណឹងជាកន្លែងសេដ្ឋកិច្ចណាស់ ៗ

វណ្ណៈ ពូវៃជាមួយលន់ ណុលណឹង មានដែលឃើញទាហានលន់ ណុល ណឹងពីណាខ្លះ?

ហ៊ុយ	មិនដែលស្គាល់ មិនដែលឃើញផង ដែលឃើញតាខេរអាវម៉ោ ចុះគ្មានឲ្យម៉ោជិតគ្នាណា ខ្លាចវៃមិនឈ្នះគេរត់ រត់គេបាញ់ងាប់ទៅ ។ គ្រាន់តាម៉ោត្រឹមនេះទៅព្រែកខាងកើតណឹង មាត់ព្រែកខាងកើតណឹងលេងគ្នាប្រាវទៅ ។

វណ្ណៈ	ចំណាំមុនហើយមានសម្បុរសំបកអីយ៉ាងម៉េចដែរ?

ហ៊ុយ	ចំណាំតែខេរអាវណឹងហីពាក់មួកដែកពាក់អីណឹងខេរអាវបាំរ៉ាខ្លាឃ្មោកណឹងទាហានហើយ ។

វណ្ណៈ	ហីក្រោយម៉ោពូទៅនៅខាងកងស៊ើបការណ៍វិញ?

ហ៊ុយ	បាទ! គេដកខ្ញុំចេញវិញ ឲ្យខ្ញុំទៅខាងស៊ើបការណ៍វិញ ។

វណ្ណៈ	យ៉ាងម៉េចបានគេដកចេញទៅខាងស៊ើបការណ៍?

ហ៊ុយ	អត់ដឹង! ដឹងគេដកយ៉ាងម៉េចគេ គេចេះតាដក ប៉ុនកាលណឹងកុំតាគេដកចេញពីណឹងដែរខ្ញុំក៏ងាប់ដែរ ឲ្យតានៅកងតាប៉ុន្មានកងទៀតងាប់! ព្រោះចូលសិតតាគ្រាប់បែកបោកគ្នា ចូលទៅសិតតាគ្រាប់បែកហ្នឹង ។

វណ្ណៈ	គេមានប្រើកាំភ្លើងដែរ?

ហ៊ុយ	កាំភ្លើងមានតាកាំភ្លើងអាកា ។ កាំភ្លើងក៏ប្រើដែរ កាំភ្លើងហើយនិងគ្រាប់បែក ។ គ្រាប់បែកឲ្យម្នាក់ម៉ាស្បោង១ ២០គ្រាប់ ជាង១០គ្រាប់ម៉ាំនាក់ទៅ ។ ហីកាំភ្លើងអាកាម្នាក់ម៉ាទុសសៀរចឹងទៅ កាំភ្លើងម៉ាដើម ។

វណ្ណៈ	គ្រាប់បែកម៉ាកអីដែរពូ?

ហ៊ុយ	គ្រាប់បែករបស់អាមេរិកណឹង គ្រាប់បែកផ្លែប៉ុម ជួនកាលគេប្រើអាគ្រាប់បែកផ្លាសស៊ីចនោះទៀត ។ ផ្លាសស៊ីចអាគ្រាប់បែកដូចសាប៊ូដុំយើងចឹង ។

វណ្ណៈ	កងស៊ើបការណ៍ណឹងគេធ្វើអីខ្លះពូ?

ហ៊ុយ	គេសម្រាប់ កងស៊ើបការណ៍ណឹងគេសម្រាប់ដូចថាទីតាំងណាដែលគេថាវៃ គឺគេឲ្យទៅយកការណ៍ទីតាំងណឹងឲ្យគេ ។ បើកាលណាយកការណ៍ទីតាំងណឹងមិនបាន យើងក៏ត្រូវទទួលខុសត្រូវដែរ ។

វណ្ណៈ	ហីចុះបើសិន... កងស៊ើបការណ៍ណឹងមានតួនាទីតាស៊ើបការណ៍ ឬក៏មានអីផ្សេងទៀត?

ហ៊ុយ	អត់មានទេធើអីទេ! ដើរតាមើលទីតាំងឲ្យគេ គេឲ្យមើលទីតាំងណាទៅមើលទីតាំងណឹងឲ្យគេហ្នឹង ។ តាពេលម៉ោប្រាំល្ងាច តាពេលស៊ីបាយស៊ីអីហើយ ទៅហើយ ។ គ្នា៣នាក់ ៤នាក់

អីម៉ាមុខសញ្ញាណឹងណាស់ឲ្យទៅមើលទីតាំង ។ ហើគេយកប្លង់គេម៉ោគូសឲ្យយើងចូលត្រូវចូលចំច្រកណាអីច្រកណា តាមមុខសញ្ញារបស់ខ្លួនយកការណ៍ឲ្យគេ ។

វណ្ណៈ គេមានវិន័យ គេមានរបៀបរបបអីយ៉ាងម៉េចដែរ សុំពូនិយាយពីរឿងរបៀបរបបស៊ើបការណ៍ណឹងមើល៍?

ហ៊ុយ វិន័យស៊ើបការណ៍គឺចូលទៅធ្វើម៉ោឲ្យស្ងៀមស្ងាត់កុំក្អក កុំឲ្យស្អី ចូលយកការណ៍ឲ្យបាន ហើមួយទៀតបើទាហានបាញ់កាំភ្លើង ធ្វើម៉េចស្តាប់កាំភ្លើងរបស់ទាហានឲ្យបាន កាំភ្លើងធំនៅកន្លែងណា ចំច្រកណា ហើមានអាកាំភ្លើងយន្តនៅចំណាទៀត បាទ! ហើកាំភ្លើងដៃចំច្រកណាខ្លះ ។ ហើគេឲ្យទៅយកការណ៍ចំអាច្រកកាំភ្លើងយន្តហ្នឹង ព្រោះតានេះគេចូលទៅគេ ឲ្យពេលទៅវៃណឹងគេឲ្យបេបុកទៅ កាំភ្លើងយន្តណឹងដើម្បីគេបោកគ្រាប់បែកចូលទៅហ្នឹង ។

វណ្ណៈ ចុះបើគេបាញ់ចឹង ពូអត់មានបាញ់តគេវិញទេ ឬក៏យ៉ាងម៉េចដែរ?

ហ៊ុយ អាណឹងបើសិនជាយើងគប់គ្រាប់បែកច្រើនទៅ គេ... គេណែ៎ អត់ហ៊ានបាញ់យើងគឺយើងវៃគេបាន ។បើថា បើចូលទៅបែកការណ៍គឺគេបាញ់យើងមុន គឺត្រូវតាគ្រោះថ្នាក់របស់គេចឹងហ្នឹង ។ ហើបើធ្វើឲ្យបែកការណ៍អ្នកស៊ើបការណ៍ក៏ត្រូវតែទទួលខុសត្រូវដែរ ។

វណ្ណៈ អាណឹងការទទួលខុសត្រូវណឹង លទ្ធផលមានអីខ្លះ?

ហ៊ុយ លទ្ធផលបើយើង... វិន័យគេមាន បើយើងធ្វើឲ្យបែកការណ៍គឺត្រូវកងពលគេផ្តន្ទារទោសយើង ។ ត្រូវឲ្យយើងទៅដ្ឋាក់ដី អីឲ្យយើងទៅធ្វើអីមួយ ដកយើងចេញស្មើណា បានស្មើណឹង ។

វណ្ណៈ វិន័យគេ អាធ្ងន់បំផុតគេឲ្យធ្វើម៉េច ហើយស្រាលបំផុតគេឲ្យធ្វើម៉េច ល្មមគេធ្វើម៉េច?

ហ៊ុយ វិន័យគេខ្ញុំមិនទាន់ឃើញអាវិន័យធ្ងន់ធ្ងរទេណាស់ ខ្ញុំឃើញតាត្រឹម បើយើងធ្វើការមិនកើតគេត្រូវដកចេញឲ្យទៅថ្មើជើង ។ ហើបើថាយើងធ្វើការកើតដូចថាមិនបះទង្គិចរឿងគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះណែ៎នេះទេ ចំពោះមុខការរបស់គេទេគឺគេអប់រំណែនាំយើង ។

វណ្ណៈ ខ្ញុំចង់ដឹងរបៀបគេផ្លាស់ ឬក៏គេផ្លាស់វេរពី បញ្ជូនមនុស្សឬក៏តម្លើងទៅកន្លែងណាមួយៗ គេពិនិត្យទៅលើអីខ្លះបានគេបញ្ជូនយើងទៅ?

ហ៊ុយ បញ្ជូនយើងទៅណា?

វណ្ណៈ ឧបមាគេចង់ដូរយើងទៅកន្លែងទាហានស៊ើបការណ៍ឬក៏វរៈផ្សេងៗមួយគេពិនិត្យទៅលើអ៊ីខ្លះ

ហ៊ុយ  គេពិនិត្យទៅលើស្មារតី បើថាស្មារតីយើងអត់កើត ដកយើងទៅ... ទៅធ្វើសេដ្ឋកិច្ចក៏បាន មិនដកធ្វើសេដ្ឋកិច្ចឲ្យធើថ្មើរជើងក៏បាន បាទ! ។ ទៅថ្មើរជើង បើថាទៅថ្មើរជើងបើវៃទៅ លែងកើត ខ្លាចទៀតដកឲ្យទៅសែងរបួសសែងអី ឲ្យរែកបាយស្លុក ដាំបាយដាំអីឲ្យគេស៊ី ។ ហើអាដាំបាយ រែកបាយស្លុកយ៉ាប់កជាងអានៅច្បាំងទៅទៀត ។

វណ្ណៈ  យ៉ាប់យ៉ាងម៉េច?

ហ៊ុយ  យ៉ាប់ត្រង់គ្រាប់ផ្លោងរហូតហ្នឹង ។ ខ្ញុំវិន័យវាច្រើនដែរខ្ញុំ រែកបាយស្លុកបាក់ស្មារតី រែកបាយស្លុកក៏ខ្ញុំធ្លាប់រែក គ្រាប់ផ្លោងតាំរហូត ហើអត់បានដេកទៀត ។ ហើបើថាម៉ោ បើថាបាយស្លុកហើយ មើលតាសភាពការណ៍គេវៃតឹងតែងគ្មានកម្លាំងគ្មានអី គេដកឲ្យជួយសែងរបួស ។ ដល់ពេលសែងរបួស អាចូលដល់កៀកៗចឹងណោះ ១០០ម៉ែត្រ ២០០ម៉ែត្រ ណឹងធាក់គ្នា រុញគ្នាទៅហើយ ។ ចុះសិតតាបាក់ស្មារតីដូចៗគ្នា បេះតាធាក់គ្នារុញគ្នាទៅ ហើយទៅសែងទៅ អញនៅក្នុងត្រង់សេរួចខ្លួន ។

វណ្ណៈ  សែងរបួសយើងចូលទៅដល់សមរភូមិដែរឬយ៉ាងម៉េច?

ហ៊ុយ  បាទ! ទៅយកទៅដល់សមរភូមិហ្នឹង ចាំតាសែងរបួសចេញម៉ោ ហើគ្រាប់ផ្លោងរហូត ៥នាទី ១០នាទី ៥នាទី ២-៣នាទីអី ផ្លោងតាំរហូតណឹង ចុះគ្រាប់៦០មាននេះអីទាហាន ផ្លោងតាំរហូតម៉ោ ។

វណ្ណៈ  ខ្ញុំចង់បន្តសំណួរពូទៀតនៅ ពូទៅវៃនៅព្រែកវាំង នៅទន្លេបាសាក់ នៅទន្លេមេគង្គ ហើទៅភ្នំពេញនោះពូនិយាយពីស្ថានភាពវៃ ពីទីតាំងវៃ និយាយដូចម៉ិញណឹង?

ហ៊ុយ  ទីតាំងវៃណឹងនៅព្រែកអ្នកតាវាំងនេះក៏វៃរបៀបរបបណឹងដែរ វៃដូចតាគ្នាណឹង ។ តានេះ គេឲ្យយើងចូលយកការណ៍មើលផ្លូវ មើលអីឲ្យគេហើយ ហើបានគេនាំទ័ពទៅ ។

វណ្ណៈ  ចឹងពេលណឹងពូចេញពីកន្លែងស៊ើបការណ៍ ឬក៏នៅកន្លែងស៊ើបការណ៍ដដែល?

ហ៊ុយ  អាណឹងនៅកន្លែងស៊ើបការណ៍ ។

វណ្ណៈ  ពូវៃនៅ មុនវៃចូលភ្នំពេញណាស់ ខ្ញុំចង់ឲ្យពូនិយាយពីស្ថានភាពវៃនៅភ្នំពេញ មុនចូលភ្នំពេញណឹងពូវៃនៅកន្លែងណាហើ ក្រោមញ្ញរបស់ពីណាដែរ?

ហ៊ុយ  ក្រោមបញ្ជារបស់កងវរៈណឹង ចេញពីកងពលម៉ោ ។

វណ្ណៈ  អាណឹងវៃនៅមុំណាដែរពូ?

ហ៊ុយ  វៃនៅតាម  ត្រើយខាងកើតនេះ  អាស់!  ត្រើយខាងលិចនេះផ្លូវជាតិលេខ២១នេះហី ហើយទៅអាចំប្រេមប្រំណឹង ។  ស្គាល់ប្រេមប្រំទេ?  អាកន្លែងផ្លូវទំបន់ទួលក្រសាំងណឹង ។ វៃតាមផ្លូវណឹង ។

វណ្ណៈ  អាណឹងនៅក្នុងស្រុកណាដែរអាណឹង?

ហ៊ុយ  មិនដឹងគេហៅស្រុកអីទេអាណឹង  អាណឹងស្រុកដង្កោរដែរមិនដឹង ។  នៅស្រុកស្អាងដែរ អាណឹង បាទ! នៅស្រុកស្អាង ។

វណ្ណៈ  ហីបន្ទាប់ម៉ោពូវៃចូលភ្នំពេញ ពូចូលតាមច្រកណាដែរ?

ហ៊ុយ  ខ្ញុំវៃៗ ដល់ហើយគេទៅជាមួយ ពួកកងវរយណឹង គេបញ្ជូនពួកខ្ញុំឲ្យទៅខាង អាណឹងចូល ទៅដល់តាខ្មៅហើយណាស់ អឺ! នៅខាងត្បូងតាខ្មៅណឹង គេឲ្យពួកខ្ញុំណឹងទៅប៉ែក ផ្លូវលេខ ៣៨ ទៅតាមផ្លូវរោងចក្រកែងណឹង ម៉ោឡើងស្ទឹងមានជ័យនេះ ។

វណ្ណៈ  ហីពូឡើងទៅតាមផ្លូវណឹងរយៈពេលប៉ុន្មានថ្ងៃបានវៃបានភ្នំពេញ?

ហ៊ុយ  តាម៉ាងៃ វៃម៉ាងៃណឹងទៅដល់ ។

វណ្ណៈ  ហីពូវៃ  ស្ថានភាពវៃដែលពេលពូចូលតាមច្រកណឹងវាមានស្ថានភាពយ៉ាងម៉េចដែរ  វៃតឹង តែងឬក៏យ៉ាងម៉េច?

ហ៊ុយ  វៃតឹងតែង  កន្លែងណឹងវៃអត់តឹងតែងទេ  ទាហានរត់ទៅរហូត ។  គ្រាន់តាដើរតាមទាហាន ទៅមិនទាន់ផង  ទាហានរត់ចូលក្រុងរហូត  ប៉ុនទៅប៉ះគ្នាទៅប៉ះនៅនេះ  ប៉ះគ្នានៅកន្លែងស្ទឹង មានជ័យណោះ ។  ប៉ះគ្នានៅស្ទឹងមានជ័យ  ហីដឹងកងទ័ពម៉ោពីណា  ស្រាប់តាច្រើនអីច្រើន មិនដឹងប៉ុន្មានសន្ធាត់  យូរៗមិនដឹងកងណាកងណីទេ  លែងដឹងកងហើយ  ដឹងតាគ្នាប៉ុន្មាននាក់ គ្នាប៉ុនណឹង ។   បើគ្នា៦នាក់ដឹងតាគ្នា៦ង៦នាក់ក្រៅពីណឹងលែងស្គាល់ដឹងកងណាកងណាទេ វៃគ្នាណឹង  ចុះដឹងប៉ុន្មានសន្ធាត់ឲ្យខ្ទាប់ពេញទាំងអស់ ។ វៃគ្នា  បើបាញ់គ្នាបាញ់មែនទែនទៅ បាញ់យកងាប់យករស់ ។  គ្រាន់តាខាងទាហាន  គ្រាន់តារថក្រោះ៥០-៦០គ្រឿងម៉ោ បាញ់គ្នាណឹង ។  ហីបើខាងពួកខ្មែរក្រហមនេះក៏មនុស្សមិនដឹងម៉ោពីណាទេ  ឲ្យខ្ទាប់ទាំងអស់ ចុះហីកាលណឹងវាសម្បូណ៍ម៉ាពួកគឺ  បេមួយដើមៗ  អាចឹងបេះតាលេងគ្នាទៅ ។  ហីខ្ញុំនៅតា ខាងកើតណោះណឹង  នៅអាកន្លែងផ្ទះថ្មណឹង  ដល់តាគេលេងគ្នាខ្លាំងចេញអាពីក្នុងផ្ទះថ្មណឹង បាញ់... ខ្ញុំសារ៉ាន់ធីណៃ ម៉ាដើម  ហីគ្រាប់បែកប៉ុន្មានគ្រាប់  បាញ់សារ៉ាន់ធីណៃផ្ទោងនឹង

គេទៅមួយទៅ ហើចូលទៅក្នុងផ្ទះគាស់ទឹកក្រូចដឹកទៅ អត់បាយស៊ីដល់គាស៊ីចឹង ។

វណ្ណៈ កាំភ្លើងដែលសម្បូរណ៍ហូរហៀរ ហើនៅឆ្នាំណា? ហើយកាំភ្លើងដែលខ្វះខាតជាងគេឆ្នាំណា? នៅពេលណាដែលកាំភ្លើងខ្វះ ពេលណាដែល...?

ហ៊ុយ កាំភ្លើងសម្បូណ៍ជាងគេចូលឆ្នាំ៧៥ ។

វណ្ណៈ ម៉េចបានសម្បូណ៍ចឹង?

ហ៊ុយ មិនដឹងគេទិញពីណាម៉ោ ។ ប៉ុនឃើញកាំភ្លើង កាំភ្លើងរបស់ចិនផង កាំភ្លើងរបស់សូវៀតផង ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយអំពីស្ថានភាព ពូថាវៃវៃណែនគាន់គាប់ណឹង ចង់និយាយពីព្រឹត្តិការណ៍ក្នុងណឹងហ្នងដែលពូមើលឃើញ រៀបរាប់ពីរបៀបវៃ របៀបអីៗដែលកើតមានឡើង?

ហ៊ុយ របៀបវៃវាវៃដូចគាគ្នាណឹង គ្រាន់តា...ខាងនោះបាញ់ម៉ោ ខាងនេះបាញ់ទៅណឹង អានេះកាំភ្លើងវា វាទំនើបវាច្រើន លេងទៅខាងណោះវាធ្ងន់ ។ ចុះអាវរថក្រោះ អ៊ឹម១១៣ចឹងម៉េចធានាជាមួយបេឈ្មះ បេ៤១ ទៅម្តងទៅទាំងហ្នងចឹង ចឹងទាហានក៏បាក់ដោយសារអញ្ចឹងដែរ ចាញ់នឹងខ្លាចគ្រាប់បេណឹង ។ ហើមួយទៀតកាំភ្លើងធំយើងយកបានខាងលន់ ណុល ណឹងក៏ផ្ទោងជួយទៅទៀត ដល់ចឹងមនុស្សវាច្របូកច្របល់ណាស់ ខាងណោះច្របូកច្របល់ត្រូវចាញ់ ។

វណ្ណៈ ពេលដែលចាញ់ណឹង ពូចូលទៅដល់ភ្នំពេញណឹងពេលណាដែរ? ហើយថ្ងៃណាដែរ?

ហ៊ុយ ចូលភ្នំពេញប្រហែលជាថ្ងៃត្រង់ ចូលថ្ងៃណឹងថ្ងៃដែលបែកណឹងហ្នង ថ្ងៃ១៧អាណឹង ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីស្ថានភាពដែលពូវៃចូលដល់ភ្នំពេញហើយ កាន់កាប់ភ្នំពេញហើយ គេឲ្យយើងធ្វើអីទៀត ហើយសកម្មភាពនៅក្នុងភ្នំពេញណឹងពូមើលឃើញថាយ៉ាងម៉េចទៀត?

ហ៊ុយ ស្ថានភាពនៅក្នុងភ្នំពេញឃើញទាហានច្របូកច្របល់ បាទ! ហើនិយាយពីប្រជាជននិយាយពីចេញឆ្វេចឆ្វាចៗ គាត់ចេញម៉ោ គេចេះតាដេញប្រជាជនឲ្យចេញណាស់ បាទ!។ ប៉ុនដល់តាយប់ខ្ញុំអត់ដឹង ព្រោះកងវរៈគេឲ្យខ្ញុំចេញទៅរៀបជួរ នៅខាងជើងណែ៎សាលាវិទ្យាល័យកន្ទែងមុខពេទ្យចិនណឹង អាខាងលិចផ្លូវណឹង អាមាំចំហៀងខាងជើងផ្លូវថ្នល់ចេះ ។ កងវរៈហៅរៀបជួរ ចុះពួកខ្ញុំមានយកអី មានតែកងហារខ្ញុំមួយគាត់យកតែទឹកស៊ីអ៊ីវប៉ុន្មាន២យួរ បាទ! យកទឹកស៊ីអ៊ីវ២យួរណឹងខ្ញុំចេះតាថាឲ្យ យ៉ីស៎! តាឯងយកអីយកម៉េស កុំ

គិតអាណឹង គិតតាប្រាសអាយុសមិនគិតទេ! ចុះទាហាននៅលើផ្ទះថ្មគេបាញ់ម៉ោណាស់ ។ បាញ់ម៉ោត្រូវប្រជាជន ចេះតាបាញ់... បាញ់កង់ទ័ពបាញ់មិនត្រូវ ហីប្រជាជនដើរចំណីង ណាស់ត្រូវប្រជាជនធ្លាយពោះធ្លាយអី ។ ហីគ្មានទៅនេះណា ខ្ញុំការពារតាខ្លួនខ្លាចទាហាន បាញ់! ។ ដើរមើលតាលើ មើលតាក្រោយ អែបតាផ្ទះ អែបតាសសរផ្ទះអ្នកស្រុកណឹង ដល់ហើយល្ងាចណឹងកងវរៈហៅ កងវរៈហៅទៅតម្រៀបជួរគ្នា ។ លេងទៅ ទៅតម្រៀប ជួរតា គ្រាន់តាតម្រៀបបានបន្តិចលេងពីលើផ្ទះថ្មម៉ោ ។ គ្រាន់គាត់សួរថា ហ៊ុយ ពួកហ៊ុយ ឯងម៉ោជុំប្តូនៅ? ខ្ញុំថានៅបងទៅ នៅណែ៎កងហារខ្ញុំម្នាក់ទៀតគាត់មិនទាន់ម៉ោ ។ យីចុះ នៅអីនៅម៉េស យូរម៉េស? ។ ហីហើយបានប្រហែល៥នាទី ខ្ញុំគ្រាន់តា គាត់សួរម្តងទៀត គ្រាន់តាបែរមើលក្រោយ ចុះគាត់កងហារ ខ្ញុំក៏ទ័ព... គាត់ត្រូវតារួតរះម៉ោ ហីគាត់អាវល់ តានៅមុជទឹក មុជអីណាផ្ទះគេ ។ គ្រាន់តាហើយ គ្រាន់តាបែរមើលក្រោយលេងព្រាក អាយ៉ាស់ជើងអាយ៉ាស់អី នេះរបួស ។

វណ្ណៈ ពីណាបាញ់ម៉ោ?

ហ៊ុយ ខាងលន់ ណុល មិនដឹងជាបាញ់អីបោកគ្រាប់បែកអីមិនដឹងទេកាលណឹង សង្ស័យបាញ់ ។

វណ្ណៈ នៅថ្ងៃណាដែរ?

ហ៊ុយ អាណឹងនៅថ្ងៃ១៧ ។

វណ្ណៈ នៅថ្ងៃតែ១ណឹង?

ហ៊ុយ បាទ! របួសខ្ញុំរបួសហីខ្ញុំរត់ គិតទៅជើងរបួសពេញទាំងអស់ ដល់ហើយអាខ្លួននេះវិនសិត តាអំបែងពេញទល់អឡូវ ដល់ហើយខ្ញុំ ខ្ញុំខ្លាចខ្ញុំ ខ្ញុំរត់ទៀត រត់នឹកឃើញថា ម៉ាសារនេះ រត់យកងាប់យករស់ រត់ទៅដល់ផ្ទះបាដោយ ។ រត់ណារត់បានតាត្រឹមផ្លូវម៉ោណឹងដួល ខ្ពោក ចុះជើងមើលជើងវាស្ពឹកហើយ ដូចជើងដីរចឹង ។ ដលស្ពឹកទៅស្មានជើងដូចជើងដីរ ចឹងទៅណាស់ ដល់ហើយដួលខ្ពោក ខ្ញុំដោះចោលអស់អាលឹង អាគ្រាប់បែក អាកាំភ្លើងអី ណាទុចចោល បោះចោលណឹងទាំងអស់ ខ្ញុំទៅតាខ្លួនឡើងវា លួនតាខ្លួនឯងទៅចូលដេក ក្រោមផ្ទះប្រឡាក់ពេញរបួសទាំងអស់ ។ ដល់ហើយបានដេកអាសប្តិឃើញបាដោយយប់ ណឹង យល់សប្តិឃើញថាពេទ្យ គេសែងខ្ញុំម៉ោក្រោយណោះ ម៉ោពេទ្យ ។ អរៗដល់ហើយ អាលឹកឡើងម៉ោង២ ម៉ោង៣ចាប់ភ័យម្តងទៀត អ៊ូ! ម៉ាសារនេះទាហានកាត់កហើយ

ម៉ាសារនេះ ។ ចុះអាសប្តិឃើញថាពេទ្យសែងរបួសយកចេញម៉ោហើយ ស្រាប់តាអរខ្លាំង ពេកស្រាប់តាអាពុកឡើងបានដឹងថាខ្លួនឯងនៅក្នុងចំណោមទាហានដដែល ។ ហើលែងទុកចិត្ត គេហើយ នឹកឃើញថាគេរត់យកតាប្រាសអាយុគេអស់ហើយ ។ ដល់ហើយខ្ញុំ យូរណាស់ ប្រហែលជាភ្លឺ ភ្លឺ! ថាគេម៉ោកកូរកកាយក្បែរផ្ទះណឹងក៏ខ្ញុំខំសំងំណឹង ហើគេថាគេដើររកខ្ញុំ គ្មានដឹងថាគ្នាឯងទាហានដើររក អត់ហ៊ានឲ្យគេដឹងទៀត ថារកលូនកាត់អាផ្លូវស៊ីងមានជ័យ ណឹងម៉ោ ។ ម៉ោក៏ម៉ោមិនរួចដែរ បើទាហាននៅពេញហើយដើរលែងរួចហើយ ។ ដល់ ហើយព្រលឹមឡើង អ្ហួស៎! ប្រផុយចេញទៅ ចេញម៉ោអ៊ឹតតាមរបសងមើល អ៊ឹតតាម របងមើលបានឃើញស្គាល់គ្នាស្រែកហៅគេជួយ បានគេម៉ោយកទៅ បានគេម៉ោសែងម៉ោ អឺដាក់ឡានបញ្ជូនម៉ោពេទ្យតាកុក អាកន្លែងខ្លោងទ្វារហ៊ុន សែន ទៅក្រាំងយ៉ូវនេះ ម៉ោដេក ពេទ្យណឹង ។

វណ្ណៈ ពូពេលដែលពូដេកយល់សប្តិ ហើខ្លាចគេកាត់កណឹងភ័យយ៉ាំងម៉េច?

ហ៊ុយ ភ័យខ្លាចទាហានកាត់ក ចុះខ្ញុំនៅខាងទ័ពណោះ ហើទ័ពខាងណោះហើទាហានខាងណោះមិនត្រូវ គ្នា ហើបាញ់គ្នា គប់គ្រាប់បែកដាក់គ្នាយប់ណឹង ដល់ចឹងភ័យខ្លួនឯង ។

វណ្ណៈ ចឹងពូដឹងស្ថានភាពក្រុងនៅពេលណឹងយ៉ាំងម៉េចទៀតពូ?

ហ៊ុយ អត់ដឹង! ព្រោះខ្ញុំដេកពេទ្យហើយ ដល់ក្រោយម៉ោចេញពីពេទ្យវិញបានគេថា ប្រជាជនគេ ជម្លៀសចេញអស់ចេញពីទីក្រុង ។

វណ្ណៈ ហើពូមានឃើញស្ថានភាពជម្លៀសប្រជាជនយ៉ាំងម៉េចដែរ?

ហ៊ុយ គេបេះ ឲ្យប្រជាជនថយចេញកុំឲ្យនៅក្នុងក្រុង ព្រោះគេត្រូវបោសសម្អាតក្រុង បោស សម្អាតទាហានកុំឲ្យនៅ ។

វណ្ណៈ ហើជម្លៀសណឹង គេយកអ្នកណាម៉ោជម្លៀសប្រជាជនណឹង?

ហ៊ុយ អត់មានអ្នកណា មានតែទ័ពណឹងបេះតាប្រាប់ប្រជាជនឲ្យថយ ឲ្យ... ស្រុកទេសនៅណាទៅ ណឹងទៅ ។

វណ្ណៈ ជម្លៀសណឹងរយៈពេលប៉ុន្មានដែរ?

ហ៊ុយ មិនដឹងដែរ ព្រោះខ្ញុំម៉ោដេកពេទ្យតាំងពីយប់ណឹងណោះ ។

វណ្ណៈ ពូមានដែលឮគេនិយាយថាម៉េចបានជាគេជម្លៀសប្រជាជនណឹងដែរ?

ហ៊ុយ   អត់! ព្រោះកាលមុនអត់មាននិយាយ ដល់ពេលវៃណឹងហ្នឹងបានជម្លៀសប្រជាជនចេញ ។

វណ្ណៈ   តាំងពីពូចូលធ្វើទាហាន រហូតដល់ពេលចូលវៃភ្នំពេញណឹង ដែលពុកគេនិយាយថាទាហាន ឬទ័ពណឹងមានអ៊ីទៅណឹងអង្គការ វាប្រយោជន៍ មានស្អីៗទាក់ទងទៅនឹងអង្គការ ទាក់ទងនឹងខ្មែរក្រហម?

ហ៊ុយ   អត់មាននិយាយអីទេ គ្រាន់ថាយើងក្រោយការដឹកនាំរបស់អង្គការ យើងតស៊ូដើម្បីវណ្ណៈកសិករគេណឹងណាស់គេនិយាយ ។ យើងរើពីអំណាចសក្តិភូមិគេណឹង ណឹងក៏គេនិយាយ ។

វណ្ណៈ   ពូពុកតាមរយៈអីខ្លះ?

ហ៊ុយ   ពុកតាមកម្មាភិបាលដែលខាងលើៗណឹងកែប្រជុំគេណែនាំ ។

វណ្ណៈ   គេតស៊ូវណ្ណៈណឹង គេតស៊ូរបៀបម៉េច ដើម្បីអី?

ហ៊ុយ   មិនដឹងដែរ ។ ចឹងបានតា ខ្ញុំចេះតាគិតមើល៍ គេនិយាយថាតស៊ូវណ្ណៈយើង...កុំឲ្យអាវណ្ណៈជិះជាន់ជាមួយ ណែ៎អ្នកក្រ ។ ចុះខ្ញុំមើលខ្លួនខ្ញុំដែរ ចុះម៉ែឪខ្ញុំ កាលពីវៀតណាមវៀតណាមនៅពេញស្រុកខ្ញុំ ចង់ការប្រាក់ឲ្យគេ ក៏គាត់មិនទៅជុះជាន់គេណា ។ ចុងការ គេគិតឲ្យ ។ ជួនកាលគេឲ្យទៅ ជួនកាលគ្នាអង្វរទៅ ក៏អត់យកពីគ្នាទៅ ។ ខ្លះឲ្យត្រីឲ្យអីហូបទៅវាចប់គ្នាហើយឲ្យតាបានលុយវិញ ។ ចុះគេនិយាយថាវណ្ណៈជិះជាន់! កន្លែងណាជិះជាន់? បើគេគ្មានជិះជាន់យើងដងណឹង ។ យើងអត់យើងទៅរកគេមុន! ។ ប៉ុនកាលណឹងមិនដឹងថាទោះបីយើងនិយាយថាម៉េចក៏គ្មានបានជាការអីដែរ ព្រោះគេថាម៉េចគឺការងាររបស់គេចឹងហើយបាទ! ព្រោះគេជាមេចឹងហើយ ។ គេថាអ្នកណាជិះជាន់យើងចេះតាអឺ អ៊ឺៗតាមគេចឹងទៅ បើមិនតាមគេ មានអី មានតា... អ្នកណាហ៊ានជំទាស់ជាមួយបាន បើគេឲ្យទៅច្បាំងចេះតាទៅ ទៅ ។ បើគេមិនឲ្យទៅអាណឹងយើងអរណាស់! ។ ប៉ុនអាកន្លែងមួយៗទាល់តាឈឺក្បាល ទាល់ដេកញាក់អីណោះ បានគេឲ្យយើងនៅបាន នៅស្ងៀមបាន បើថាត្រឹមម៉ាល្ហមៗទេ បញ្ជូនឡើងទៅវៃទាំងអស់ណឹងគ្មានឲ្យនៅទេ ។ ហឹតាឈឺញឹកពេក គេថាពុតទៀត ពិបាកណាស់! ។ ប្រហែលខ្ញុំចៃពោះខាំពេញខ្លួនដងនៅ... អត់ស្លៀកខោ ស្លៀកតែកន្សែងនៅតាគេមិនឲ្យខ្ញុំម៉ោដេកពេទ្យ ។

វណ្ណៈ   ពូនិយាយរឿងវៀតណាមនៅពេញស្រុកណឹង ពូឃើញវៀតណាមនៅស្រុកខ្មែរយើងតាំងពីឆ្នាំណា ហើយរហូតដល់ពេលណាដែរ?

ហ៊ុយ ខ្ញុំឃើញកាលពីខ្ញុំកើតម៉ោណោះ ។ មិនមែនត្រឹកខ្ញុំកើតម៉ោទេ ត្រឹមខ្ញុំដឹងក្ដី ។ ដឹងក្ដីឃើញវៀតណាមនៅក្បែរភូមិខ្ញុំណឹងបាទ! ។

វណ្ណៈ គេម៉ោក្នុងទំនាក់ទំនងយ៉ាងម៉េចដែរនៅស្រុកខ្មែរយើងណឹង?

ហ៊ុយ គេម៉ោនៅ... ទឹកដីកន្លែងណឹងមិនដឹងគេយ៉ាងម៉េចអីយ៉ាងម៉េចខ្ញុំមិនដឹងដែរ ។ ប៉ុនឃើញម៉ាប្លង់ប៉ុនណាណឹណឹងគេកាន់កាប់ គេនៅហ្នឹង ។

វណ្ណៈ ជាមុនស្ស បែបណា ជា...ជាទាហាន ឬក៏ជា...?

ហ៊ុយ ជាប្រជាជនណឹង មានទាហានណាកាលណឹង សិតតាប្រជាជន ។

វណ្ណៈ ហីគេមានម៉ោ... ក្រៅពីរកស៊ីគេមានធ្វើអីទៀតនៅ?

ហ៊ុយ អត់មានទេ គេម៉ោរកស៊ី ដាក់មងដាក់អី ចាប់ពោះចាប់អីណឹង អត់មានម៉ោធ្វើអីណា ។

វណ្ណៈ នៅក្នុងទំនាក់ទំនងយោធាជាមួយពូ ពូអត់ដែលឃើញមានវៀតណាមទៅជាមួយទេ?

ហ៊ុយ បាទ?

វណ្ណៈ នៅក្នុងយោធារបស់ពូណឹងដែលមានឃើញវៀតណាមលូកដៃចូលទេ?

ហ៊ុយ អត់មានទេ ។

វណ្ណៈ ពេលវៃឈ្នះភ្នំពេញហើយ ពេលពូដេកពេទ្យហើយពូទៅកន្លែងណាទៀតពូ?

ហ៊ុយ វៃឈ្នះភ្នំពេញដេកពេទ្យ ចេញពីពេទ្យហើយទៅកង អគ្គភាពវិញ ។

វណ្ណៈ អាណឹងអគ្គភាពណឹងយ៉ាងម៉េចដែរ?

ហ៊ុយ ទៅកងវរៈរបស់ខ្ញុំណឹង កងវរយរបស់ខ្ញុំណឹង បាទ ។

វណ្ណៈ ហីហេតុអីបានជាគេឲ្យពូទៅការពារស្ថានីយ៍ទឹកល្អក់ទៅវិញ?

ហ៊ុយ ខ្ញុំអត់ដឹងដែរ ព្រោះកងនៅណឹង ដល់ពេលខ្ញុំទៅគេបញ្ជូនទៅ បញ្ជូនទៅកន្លែងកងពលទៅកងពលគេបញ្ជូនទៅកន្លែងវរៈសេនាធំ វរៈសេនាធំបញ្ជូនទៅវរៈសេនាតូច វរៈសេនាតូចបញ្ជូនកន្លែង អាអនុសេនាធំណឹងហ្នឹង ទៅកងវរយណឹង ។

វណ្ណៈ ទាហានកងពល៧០៣ក្ដាប់កន្លែងណាខ្លះនៅទីក្រុងភ្នំពេញ?

ហ៊ុយ បាទ?

វណ្ណៈ ទាហាន៧០៣ ក្ដាប់ផ្នែកណាខ្លះនៅទីក្រុងភ្នំពេញ ។

ហ៊ុយ មិនដឹងក្ដាប់ផ្នែកណាព្រោះទាហាន វា... វាសម្រាប់តាទាហានណឹងហ្នឹង ។ កាលនោះគេឲ្យ

យាមចឹងដែរ ។ គេដកយកទៅវៃជាមួយឃ្លួនវិញអស់ទៀតទៅ ជាមួយវៀតណាមណឹង ។

វណ្ណៈ ពូថាទៅរៀបជួរណឹងមានន័យថាយ៉ាងម៉េចពូ?

ហ៊ុយ គេឲ្យរៀបជួរដើម្បី មិនដឹងទៅណាគេទៀតទេ ទទួលទាហានវៃណឹងបាដោយទៅ អាស់! ទទួទាហានបាញ់ ប្រោកគ្រាប់បាដោយណឹងទៅ វាអាគាត់អាគាយគ្នារបួសខ្ទេចខ្ទីអស់ អាលីងទៅ អាណាងាប់ៗទៅ អាខ្លះដាប់ម៉ាកំណាត់ខ្លួនទៅ ។ អ្នកណាប្រោកចំ គ្រាប់បែក ដូចថាម៉ោចំក្បែរខ្លួនចឹងដាច់មាកំណាត់ខ្លួនទៅ ។ ណានេះរបួស អ្នកណានេះធ្លាយពោះនៅ ងាប់ណឹង ។

វណ្ណៈ ហឹពាក្យរៀបជួរណឹងមានន័យថាយ៉ាងម៉េច?

ហ៊ុយ ជាន័យរបស់ទាហានគេឲ្យតម្រង់ជួរណឹងហ្នឹង តម្រង់ជួរដល់ហើយគេឲ្យទៅណា ទៅណឹង ជាមួយគេ ទៅទាំងជួរចឹង ។

វណ្ណៈ ពូនៅទំបន់ទឹកណឹងមើលធ្វើខ្លះ? ហើយនៅរយៈពេលប៉ុន្មានដែរពូ?

ហ៊ុយ នៅកន្លែងរដ្ឋករទឹកណឹង មិនដឹងជាប៉ុន្មានខែ ប៉ុនពួកខ្ញុំណឹង គេឲ្យម៉ោធ្វើជម្រាលដីនៅកន្លែង ចាក់អង្រែនេះ ធ្វើស្រែ ឲ្យធ្វើស្រែណឹង ។ ហើយយប់ ល្ងាចទៅវិញទៅនៅកន្លែងអាវដ្ឋករ ទឹកណឹង គេឲ្យយាម យាមទឹកយាមអីណឹងណាស់ ។

វណ្ណៈ ទឹកគេប្រើប្តូទឹកយ៉ាងម៉េច?

ហ៊ុយ ទឹកប្រើ ទឹកប្រើក្នុងភ្នំពេញ ។

វណ្ណៈ ទឹកហូបណឹង?

ហ៊ុយ បាទ! ។

វណ្ណៈ ហើយធ្វើស្រែនៅចង្រែណឹង នៅឆ្នាំណាដែរពូ?

ហ៊ុយ ណឹងឆ្នាំ៧៥ - ៧៦ ។

វណ្ណៈ ពេលឈ្នះហើយណឹង?

ហ៊ុយ បាទ! ។

វណ្ណៈ ហឹបន្ទាប់ម៉ោគេដកទៅស៊ឹងព្រែកគ្នោត ទៅធ្វើអី?

ហ៊ុយ បាទ! ឲ្យម៉ោនៅអាកន្លែងភូមិស្អឹគេ ម៉ោធ្វើស្រែណឹង ។

វណ្ណៈ ពេលណឹងគេយល់ថាយ៉ាងម៉េចដែរ បានឲ្យកងទ័ពឈប់ទៅវៃហើយដកទៅធ្វើស្រែចឹង?

ហ៊ុយ អាណឹងទ័ពលែងច្បាំងហើយគេអត់ឲ្យទំនេរ គេឲ្យទៅធ្វើដី ធ្វើអី ធ្វើស្រែ ។

វណ្ណៈ ប៉ុន្តែមានទ័ពផ្សេងទៀតគេដកទៅកន្លែងនាផ្សេងទៀតទេ ក្រៅពីធ្វើស្រែណឹង?

ហ៊ុយ អត់ដឹង! អត់ដឹង!

វណ្ណៈ បន្ទាប់ពីធ្វើស្រែណឹងហើយពូទៅណាទៀតពូ?

ហ៊ុយ បន្ទាប់ពីធ្វើស្រែណឹងគេដកខ្ញុំឲ្យទៅកន្លែង គេហៅខ្ញុំឲ្យទៅ ថាឲ្យខ្ញុំទៅអគ្គភាពអាមាំរីន បាទ! ដល់ទៅដល់អាកន្លែងផ្សារថ្មី គេបញ្ជូន ឌុបខ្ញុំម៉ោយកអាកន្លែងណឹងបាដោយ ។

វណ្ណៈ កាលណឹងពូថាពីណាគេអ្នកឌុបពូទៅ?

ហ៊ុយ **ហ៊ី** ហ៊ីកន្ទុញកងវរៈ ។

វណ្ណៈ ហ៊ី ណឹងគាត់កងវរៈ? ប្រធានវរៈលេខប៉ុន្មានដែរ?

ហ៊ុយ ១០០ អឺ អានេះ៧០៤ ... អឺ ណឹងហើយ**៧០៤** ។

វណ្ណៈ គាត់ប្រធានកងឬក៏យ៉ាំងម៉េច?

ហ៊ុយ បាទ! ប្រធានវរៈហ្នឹង ។

វណ្ណៈ ប្រធានវរៈធំ ឬក៏តូច?

ហ៊ុយ កងវរៈគ្នាប៉ុន្មានរយណាក់ណឹង ។

វណ្ណៈ អាណឹងគេហៅវរៈសេនាធំ ឬក៏វរៈសេនាតូច?

ហ៊ុយ វរៈសេនាតូច ។

វណ្ណៈ ហ៊ីពូទៅដល់ទួលស្លែងណឹង ទៅដល់ខែណាឆ្នាំណា ហើយទៅធ្វើយ៉ាំងម៉េច?

ហ៊ុយ ចឹងបានខ្ញុំថាគេផ្លាស់ខ្ញុំឲ្យទៅកងទ័ពអាម៉ារីនណឹង ដល់ហើយយប់ណឹងគេឌុបខ្ញុំយកម៉ោកន្លែងណឹង ។ គេថាខ្ញុំមានរឿងមានអ៊ាវអី ។ «មិត្តឯងមានរឿងណាស់!» ខ្ញុំថាៈខ្ញុំមានរឿងអី? «ទេ! អត់មានរឿងយ៉ាំងម៉េចទៅដល់នោះគង់តែដឹងទេ» ។ ចុះក្រែងបងឯងឲ្យខ្ញុំទៅយកខ្ញុំទៅខាងអាម៉ារីន? ។ «អាម៉ារីនអី! ទៅដល់នោះគង់តែដឹងទេ!» ។ ដល់ហើយយកខ្ញុំចូលម៉ោកន្លែងទួលស្លែងនៅក្នុងឆ្នាំ៧៧ ។

វណ្ណៈ មានចាំថ្ងៃខែដែរពូ?

ហ៊ុយ អត់ចាំទេ ។

វណ្ណៈ ប្រហែលជានៅដើមឆ្នាំ ឬក៏នៅចុងឆ្នាំ?

ហ៊ុយ	នៅដើមឆ្នាំ ។

វណ្ណៈ	ពេលដែលពូទៅដល់ទួលស្លែងដំបូងណឹងគេឲ្យពូធ្វើអីខ្លះ? ហើយនៅកន្លែងណាខ្លះ?

ហ៊ុយ	អត់មានធ្វើអីទេ ដំបូងដៃម៉ោ ក្នុងប៉ុន្មានថ្ងៃណឹងគេឲ្យខ្ញុំនៅស្ងៀម បាទ! បាយហើយដេក បាយហើយដេកណឹង ។ ដល់ក្រោយម៉ោបានគេដកមនុស្សពីអគ្គភាពកង់ទ័ពនេះយកទៅទៀតបានគេឲ្យពួកខ្ញុំ ឲ្យខ្ញុំនេះយាមដែរ ។ ឲ្យខ្ញុំយាមបានគេរៀបចំជាក្រុម១ហ្នឹង ។ យកទៅការពារណឹងទាំងអស់ហ្នឹង ។

វណ្ណៈ	មានក្រុមអីខ្លះពូ នៅរៀបចំជាក្រុមណឹង?

ហ៊ុយ	កាលនោះជាក្រុមការពារហ្នឹង ។

វណ្ណៈ	ការពារ ឬក៏មានក្រុមអីផ្សេងទៀតដែរ?

ហ៊ុយ	អត់មានទេកាលណឹង ។

វណ្ណៈ	គ្នាប៉ុន្មាននាក់ដែរម៉ាក្រុមណឹង?

ហ៊ុយ	យី! ម៉ាក្រុម ម៉ាក្រុមគ្នាជាង១០នាក់ ។

វណ្ណៈ	ហីពេលណឹងពូនៅទាក់ទងជាមួយទាហានដដែលឬក៏យ៉ាងម៉េច?

ហ៊ុយ	កាលណឹងវាជាទាហាន ទាហានគឺថាខ្មី ថាខ្មីទាហានយកទៅយាម ។ ហីដល់យាមយូរទៅគេលែងឲ្យម៉ោវិញគេឲ្យនៅណឹងបាដោយ ។

វណ្ណៈ	ចុះពេលណឹងទំនាក់ទំនងអីយ៉ាងម៉េចទៀតជាមួយទាហាន?

ហ៊ុយ	ទំនាក់ទំនងវាលែងទាក់ទងគ្នាបាន មាន... បើគេដកទៅណោះទាំងអស់គ្នាហើយ អ្នកណានៅកន្លែងណានៅកន្លែងណឹង អាណឹងដាច់ពីទាហានអស់ហើយណាស់ ។

វណ្ណៈ	ពូចូលទៅស-២១ណឹង ទៅខាងកងការពារណឹងគេ មានគ្នាប៉ុន្មាននាក់ ហើយគេធ្វើអីខ្លះ?

ហ៊ុយ	កាលមុនគ្នាប៉ុន្មាន ប្រហែលជាគ្នា២០០នាក់កាលណឹង ។

វណ្ណៈ	នៅស-២១ណឹង?

ហ៊ុយ	បាទ! គ្រាន់តាអ្នកយាមណាស់ ។ ប៉ុនដល់ក្រោយម៉ោគេដក អ្នកណាចេះអក្សរគ្រាន់ៗបើគេដកយកចូលទៅសួរចម្លើយអីផង ហីនៅយាមទៅ ។

វណ្ណៈ	មានប៉ុន្មានផ្នែកនៅក្នុងណឹង?

ហ៊ុយ	នៅក្នុងណឹងមាន ផ្នែកយាម ផ្នែកសួរចម្លើយ មានតា២ផ្នែកណឹង អ្នកចាប់អ្នកអី អ៊ូ!មាន

អ្នកនៅកន្លែងជើងឯកនេះ ។

វណ្ណៈ ជើងឯកណើងធ្វើអី?

ហ៊ុយ ជើងឯកណើងជាអ្នកសម្រាប់សម្លាប់ ។

វណ្ណៈ ហើពូនៅកងការពារណើងរហូតទៅដល់ពេលណាទៅ?

ហ៊ុយ ដល់ពាក់កណ្តាលឆ្នាំ៧៨ ។

វណ្ណៈ ចឹងពូមានផ្លាស់ប្តូរអីទៀតដែរ អីក៏នៅការពាររហូត?

ហ៊ុយ ខ្ញុំនៅខាងផ្នែកការពារណើង ហើផ្នែកខាងចាំទទួលអ្នកទោស និងចាំដូចថា តា**ឌុច** ហើតា**ហ៊ី** ណើងគាត់គេប្រាប់ឲ្យចាប់ពួកណា ពីកងពលណា ពីអគ្គភាពណា គឺគាត់នាំពួកខ្ញុំទៅ ។

វណ្ណៈ នៅក្នុងគុកទួលស្លែងណើងពីណាគេធំជាងគេ ហើយបន្ទាប់ម៉ោ ៗ ៗពីណាទៀត?

ហ៊ុយ **តាឌុចធំជាងគេ ។ ឌុចហើយតា ហ៊ី ។ តាហ៊ីហើយបាទបង ហ៊ុយ ។ បាទ!ហើបាន ពួកតាចាន់ ពួអីនេះខាងផ្នែកសួរចម្លើយណើង ។** ហើអាពួកការពារ ។

វណ្ណៈ ការពារតាចាន់ដែរ?

ហ៊ុយ អត់ទេ

វណ្ណៈ ការពារពីណាគេ?

ហ៊ុយ ផ្នែកការពារ**តាហ៊ីណើង ប្រធានកងការពារ**ដល់ហើយប្រធានការពារខាងនេះណើង**ប៉េង** ។

វណ្ណៈ ហើយបានដូរទៅប៉េងវិញ?

ហ៊ុយ បាទ!

វណ្ណៈ ហើហ៊ីណើងដល់ពេលដូរ ហ៊ីទៅណាទៀតទៅ?

ហ៊ុយ ហ៊ីនៅណើង ។ ហ៊ីណើងជាអនុប្រធានផ្នែកការពារទាំងអស់នៅណើងហ្នឹង ។ ជាប្រធានមន្ទីរ ណើងផងហើយការពារណើង នៅលើគាត់កាន់កាប់ ។

វណ្ណៈ មន្ទីរស-២១ណើងក្រៅពីឌុចម៉ោ មានពីណាគេដែលធ្វើការត្រួតពីលើស-២១ណើង?

ហ៊ុយ អត់ដឹង ។

វណ្ណៈ ពូមានដែលឃើញមនុស្សអីម៉ោ...?

ហ៊ុយ អត់មានទេ មានតែ **សុន សេន** កាលណើងចូលទៅម្តង ចូលទៅបង្រៀន បង្រៀនអាផែ ដូចផែ១៧មេសាចឹងណាស់ ទៅបង្រៀនពួកខ្ញុំ ។ ហើខ្ញុំដល់ឃើញចឹង ខ្ញុំនឹកឃើញថាខ្លួនខ្ញុំ

ខ្លាចគាត់មិនរួចគ្រោះថ្នាក់កន្លែងណឹង ចឹងសុំគាត់ឲ្យហើយ ព្រោះកាលណឹងវាតឹងតែងដែរណាស់ ខ្ញុំសុំសុន សេន ខ្ញុំសុំទៅចំពវិញ ។ អត់ឲ្យខ្ញុំទៅ ។

វណ្ណៈ ពូសុំផ្ទាល់ហ្នឹង?

ហ៊ុយ បាទ! ចុះឃើញថាគាត់ម៉ោណឹងមានគោគាត់ធំជាង ។ ខ្ញុំសុំផ្ទាល់មនុស្សពេញទាំងអស់ក្នុងម៉ាកន្លែងរៀនសូត្រណឹង ដល់ហើយខ្ញុំសុំហ្នឹង ថាអ្ហ៊ឹស! ឡើងឈរសុំគាត់ហ្នឹង សុំពីឆ្ងាយទៅហ្នឹង" អ៊ីៗ! ខ្ញុំសុំអ៊ីឯងទៅចំពវិញហើយ ខ្ញុំលែងនៅនេះ" ។ គាត់ថា "អ្ហូស! អត់ឲ្យទៅទេ" ។ បានខ្ញុំថា អត់ឲ្យទៅខ្ញុំសង្ស័យខ្លាចទៅវៃជាមួយយួនខ្លាចយួនចាប់បាន វាដឹងបួនដឹងអីកន្លែងណឹងណាស់ ចឹងបែបមិនឲ្យទៅដោយសារចឹងហើយ ។ ខានបានទៅ ។ នឹកឃើញថាងាប់បើងាប់ ក៏ងាប់នៅសមរភូមិល្អជាងអាងាប់...ពេលដែលគេឆ្លើដាក់ឆ្លើយអី ជាប់គុកជាប់អីវេទនា ជៀសងាប់មិនរួច ។ ចឹងសុខចិត្តទៅងាប់នៅចំពវិញល្អជាង ។

វណ្ណៈ ចុះក្រៅពីខុចណឹងមានឃើញពីណាម៉ោទៀតដែរ អ៊ុះ! ក្រៅពីសុន សេន ណឹងមានពីណាម៉ោទៀតទេ?

ហ៊ុយ អត់ អត់ដឹង!

វណ្ណៈ អ្នកទោសដែលច្រើនចាប់ណឹងម៉ោពីណាខ្លះពូ?

ហ៊ុយ គ្រប់! គ្រប់កន្លែងទាំងអស់ គ្មានថាកន្លែងណាមួយទេ គ្រប់កន្លែងទាំងអស់ គ្មានថាកន្លែងណាមួយទេ គ្រប់កន្លែងហ្នឹង ។

វណ្ណៈ ចុះពូមានដែលឃើញទាហាន៧០៣ចូលដែរ?

ហ៊ុយ ទាហាន៧០៣ក៏មាន ។

វណ្ណៈ ហើពូមានដែលស្គាល់គេដែរ ស្គាល់អ្នកដែលគេចាប់ទៅដែរ?

ហ៊ុយ ចឹមិនស្គាល់ ។

វណ្ណៈ ៧០៣ណាស់?

ហ៊ុយ បាទ!

វណ្ណៈ ពូរាប់មើល៍ មានចាំឈ្មោះពីណាខ្លះដែរ?

ហ៊ុយ អឺ! មួយដែលថាប្រធានកងវរយខ្ញុំក៏ចាប់យកទៅដែរ ។

វណ្ណៈ ឈ្មោះអីដែរ?

ហ៊ុយ **នួន** ។

វណ្ណៈ ស្អីគេនួន?

ហ៊ុយ ដឹងស្អីគេនួនទេ ។

វណ្ណៈ គាត់ប្រធានកងវរយ?

ហ៊ុយ បាទ! កងវរយខាងផ្នែកកងស៊ើបការណ៍ណឹង ។

វណ្ណៈ ហើយពីណាទៀត?

ហ៊ុយ ដឹងអ្នកណាៗទៀតទេ ។ ហីអាទៅពួកកងវរយ កងអី ការពារពួកខ្ញុំនេះក៏... ស្លាប់ក្នុងណឹងហ្នឹង ។

វណ្ណៈ អ្នកធ្វើការជាមួយពូណឹង?

ហ៊ុយ បាទ!

វណ្ណៈ ហីពេលដែលពូឃើញគេចឹងពូមានអារម្មណ៍យ៉ាងម៉េច ហីហ៊ានទៅនិយាយជាមួយគេទេ?

ហ៊ុយ បាទ! ព្រោះតែនឹកឃើញចឹងហើយបានខ្ញុំសុំ សុន សេន ណឹងទៅទ័ពវិញណឹង ។ បើកងវរយ កងអីគាត់ធ្លាប់នៅអង្គភាពជាមួយខ្ញុំ ហីគាត់ធ្វើធំជាងខ្ញុំនៅកន្លែងណឹងក៏ជាប់ដែរ ។ អ្នកសួរចម្លើយក៏ជាប់ ហ្នឹកការពារក៏ជាប់ ។ បាទ! កាលមុនមនុស្សច្រើនដូចខ្ញុំបាននិយាយចឹង មនុស្សច្រើន ហីដល់ហើយ ក្រោយម៉ោនៅសល់គ្នាតិចតួច គេចាប់ដាក់គុកអស់ ។

វណ្ណៈ នៅក្នុងកងការពារគេឲ្យពូធ្វើអីខ្លះ?

ហ៊ុយ កងការពារ ខ្ញុំនៅផ្នែកខាងក្រៅណោះ ហីខាងក្នុងនៅលើ**ប៉េង** ហី **ស៊ី** អ្នកយាមខាងក្នុងនោះ ។ ហីខ្ញុំនៅចាំទទួលអ្នកទោសនៅខាងក្រៅណោះ ។ ហីហើយគេឲ្យខ្ញុំជួយចល័តម្តងម្កាលពេលដែលគ្មានការងារធ្វើគេឲ្យខ្ញុំចូលជួយមើលគេអ្នកយាមណឹងណាស់ គ្រាន់ដើរតាមខាងក្រៅណឹងមើល ។ ដល់ខ្ញុំដើរខាងក្រៅណឹងមើលហើយ ខ្ញុំប្រាប់ ប៉េងថាខ្ញុំមើលហើយ ហីមើលខ្លួនឯងទៅខ្ញុំទៅវិញហើយ ។ ចុះខ្ញុំនៅយាមខាងក្រៅណោះដែរ ម៉ាក្រុមខ្ញុំក៏ខ្ញុំនៅយាមខាងក្រៅណោះដែរមានខ្ញុំអត់យាមណា ។ ម៉ោវិញដេក ជួនកាលម៉ោវិញដល់ម៉ោងខ្ញុំយាមយាមបន្តទៅ ម៉ាម៉ោងដាស់ទៅ ។ ដាស់ពួកអ្នកនៅជាមួយណឹងគេយាមវិញទៅខ្ញុំដេកវិញ ។

វណ្ណៈ នៅណឹងពីណាគេដែលបញ្ជាលើពូផ្ទាល់?

ហ៊ុយ **បញ្ជាលើខ្ញុំផ្ទាល់គឺតាហីណឹងហ្នឹង តាហី ហើយនិងតាឌុច ។**

វណ្ណៈ ហា ហើយនិង ឌុចដែលប្រើពូឲ្យធ្វើអីខ្លះពូ?

ហ៊ុយ ឲ្យខ្ញុំចាប់អ្នកទោស ចាប់អីណឹង ។ គាគាត់ទៅហៅក្រុមពួកខ្ញុំទៅ ទៅជាមួយគាត់ ទាំងខ្ញុំទាំងអាកូនក្រុមនៅជាមួយខ្ញុំណឹង ។

វណ្ណៈ ចឹងពូប្រធានក្រុម អីយ៉ាងម៉េច?

ហ៊ុយ **ខ្ញុំប្រធានក្រុម** ម៉ាក្រុមណឹងផង ហឹ**អនុប្រធានក្រុម**មួយទៀត ។

វណ្ណៈ ឈ្មោះអីគេដែរ?

ហ៊ុយ ឈ្មោះ **ស្រ៊ឹម** ។ ប៉ុន**ស្លាប់ហើយ**វៃគ្នានៅលិចណោះ ។

វណ្ណៈ គេទៅចាប់ណឹងគេមានសី្អខ្លះយកទៅចាប់ជាមួយ ហើយប្រើឧបករណ៍សី្អខ្លះ?

ហ៊ុយ គេយកកាខ្មោះ យកអីទៅ ។

វណ្ណៈ ហឹគេបណ្តើរម៉ោប្តុក៏យ៉ាងម៉េច?

ហ៊ុយ ពេលទៅគេយកឡាន យកឡានទៅ ដល់ហើយចាប់នៅផ្ទះគេណឹង ជួនកាលគេចាប់ខ្លួនគេណោះ យើងគ្រាន់តាទៅទទួលពីគេដាក់ឡានម៉ោ ។

វណ្ណៈ ដាក់ឡានអីគេដែរពូ?

ហ៊ុយ ឡានគេហៅ ឡង់រ៉ូវែ គេណឹង ដឹបូលដិត ដឹបូលក្រណាត់ដិត ។

វណ្ណៈ ចាប់ម្តងៗដាក់ប៉ុន្មាននាក់ដែរ?

ហ៊ុយ វាមិនទៀង ជួនកាល៤-៥ នាក់២-៣នាក់ ៦-៧នាក់ ។ ហឹបើមនុស្សគេបញ្ជូនម៉ោជួនកាលម៉ោ៤-១០នាក់ ២០នាក់អីចឹងទៅ ។

វណ្ណៈ ភាគច្រើនពូទៅចាប់ទៅដល់ណា?

ហ៊ុយ នៅក្នុងភ្នំពេញនេះ ។

វណ្ណៈ ហឹអ្នកដែលចាប់ណឹងជាមនុស្សប្រភេទណាដែរ?

ហ៊ុយ ចុះគេអត់ឲ្យដឹងណា គេគ្រន់តាថាខោនាវនេះ រាងរៅនេះ មុខមាត់នេះ យើងចូលទៅចាប់ហ្នឹង បាទ! ។ ហឹបើថាចាប់ឲ្យមានគ្រោះថ្នាក់អី ត្រូវទទួលខុសត្រូវ ។

វណ្ណៈ ជាមួយអ្នកទោសណឹងពូដែលមានធ្វើអីជាមួយអ្នកទោសដែរ?

ហ៊ុយ ខ្ញុំមិនដែលធ្វើអីគេទេ ព្រោះគេមិនឲ្យធ្វើអីផងគេមិនឲ្យសួរឈ្មោះសួរអីទៀតណាស់ ប៉ុនតាក្នុងការកត់គឺឲ្យសួរកត់បាន កត់ឈ្មោះណាស់ ។ កត់ឈ្មោះហើយគឺត្រូវបញ្ជូនឲ្យគេ អត់

មានសួរអីទៀតទេ ហីគ្មានធ្វើអីគេទៀតទេ ត្រូវបញ្ជូនយកទៅឲ្យគេ ។ កត់ទាំងឈ្មោះ ទាំងមនុស្សបញ្ជូនទៅឲ្យគេ គេកត់ហើយគេមើលឈ្មោះក្នុងណឹង... **ធី** បញ្ជូនឲ្យទៅធីទៅ ធីនៅណឹង ។

វណ្ណៈ ធី ណឹងខាងអីគេ?

ហ៊ុយ ធីណឹងនៅខាងកាន់បញ្ជីនៅណឹង ។

វណ្ណៈ កាន់បញ្ជីអ្នកទោសហ្នឹង?

ហ៊ុយ បាទ!

វណ្ណៈ ពូដែលទៅ**ជើងឯក**ដែរពូ?

ហ៊ុយ ទៅ! ខ្ញុំដឹកទៅជាមួយតាហ៊ី ជាមួយតាឌុចណឹង ។ ពេលនេះគេឲ្យពួកខ្ញុំការពារដឹកយកទៅ ។

វណ្ណៈ ហីពូមានដែលឃើញអី ព្រឹត្តិការណ៍នៅជើងឯកណឹងដែរ ដែលពូជួបប្រទះ?

ហ៊ុយ ទៅដល់កន្លែងណឹងមានតាកត់ឈ្មោះ កត់អីបញ្ជូនយកទៅឲ្យគេ គេយកទៅសម្លាប់ ។

វណ្ណៈ ពីណាខ្លះដេលសម្លាប់នៅណឹង?

ហ៊ុយ អឺ! **ប្រធានក្រុមណឹង គេង** ។

វណ្ណៈ គេងអ្នកសម្លាប់ណឹង?

ហ៊ុយ គេង ហើយនិងក្រុមរបស់គេណឹង ម៉ាក្រុមគេណឹង ។

វណ្ណៈ សុំទោស ខ្ញុំសុំសួរពូកាលដែរពូនៅធ្វើណឹងពូដែលធ្លាប់... នៅជើងឯកណឹងណាស់ ធ្លាប់... សម្លាប់ ធ្លាប់វៃអីដែរ?

ហ៊ុយ កាលណោះតាឌុចគាត់បាន ពេលដែលខ្ញុំកត់ឈ្មោះកត់អីណឹង ។ ដល់ហើយគាត់ហៅខ្ញុំសួរទៅ ទៅសួរនៅកន្លែងគេវៃណឹងណាស់ ។ សួរថា« **ហ៊ុយ ឯងដាច់ខាតអីមិនដាច់ខាត?** » ខ្ញុំថា« **ដាច់ខាតបង!** » ។ ចុះបើយើងថាមិនដាច់ខាត ព្រោះនិយាយម៉ាត់ណាម៉ាត់ណឹង ឌុចមិនមែនចេះតានិយាយថា យើងនិយាយលេងនិយាយអីទេ គេថា គេអ្នកធំគេមុខការ គេវ៉ា ថាម៉េចចឹងហើយណាស់ ។ ចុះប្រហែលបងប្អូន ប្អូនថ្លៃគេដងគេសម្លាប់! ចុះទម្រាំខ្ញុំស្អី! គេមិនហ៊ានសម្លាប់ប៉ុនណឹងវ៉ិនណឹង ។ ដល់ហើយខ្ញុំថា «ដាច់ខាតបង!» ។ «**បើដាច់ខាតសាកមើល៍! ហាំនវៃបួអត់ ?**» ។ វៃខ្ញុំទាញដែកពីគេម៉ោ យកម៉ោដាក់ទៅ ។ ដាកហើយខ្ញុំបោះដែកឲ្យគេ ដល់ហើយខ្ញុំចេញម៉ោវិញម៉ោ ទៅអាកន្លែងកត់ឈ្មោះឲ្យគេ

វណ្ណៈ មុនណោះចឹង?

ហ៊ុយ បាទ!

វណ្ណៈ ចាន់ ចក្រីគាត់នៅកាន់ខាងណាដែរ?

ហ៊ុយ គាត់កាន់ខាងកងទ័ពបូព៌ា ។

វណ្ណៈ កាលមុន ចាន់ ចក្រី?

ហ៊ុយ គាត់ខាងកងទ័ពបូព៌ា ប៉ុនគាត់មិនដឹងយ៉ាងម៉េចអីយ៉ាងម៉េច ស្រាប់គាត់ម៉ោកាន់កាប់ គាត់ម៉ោប្រកាស៧០៣ណឹង ។

វណ្ណៈ ចុះសោភឹមនៅបូព៌ាមានតួនាទីអីដែរ?

ហ៊ុយ គាត់ប្រធានភូមិភាគបូព៌ា ។

វណ្ណៈ ប្រធានភូមិភាគ ដល់ចាន់ ចក្រីគាត់...?

ហ៊ុយ បាទ! គាត់ប្រធានកងទ័ព ។

វណ្ណៈ ខ្ញុំចង់សួរពីលក្ខណៈសម្បត្តិ អត្តចរិកមនុស្សនៅក្នុង៧០៣ណាស់ ក្រៅពីតាណាតមានពីណាទៀត?

ហ៊ុយ តាណាត តាពីន តាអីណឹង ។

វណ្ណៈ តាណាត ហ៊ី តាពីន អ្នកណាធំជាង?

ហ៊ុយ តាណាត ធំជាង តាពីន ។

វណ្ណៈ តាណាត កាន់៧០៣ តាំងពីឆ្នាំណាទៅដល់ឆ្នាំណា?

ហ៊ុយ ដឹងតាំងពីឆ្នាំណាម៉ោ ខ្ញុំចូលទៅឃើញតាគាត់ ។

វណ្ណៈ មានដែលឃើញតាណាតទៅគុកទួលស្លែងដែរ?

ហ៊ុយ អត់!

វណ្ណៈ តាណាត អត់នៅគុកទួលស្លែងទេ?

ហ៊ុយ អត់ ។

វណ្ណៈ ហ៊ីតាពីន តាណាត ណឹងមនុស្សយ៉ាងម៉េចដែរ?

ហ៊ុយ ទេ! មិនដឹងមនុស្សយ៉ាងម៉េច ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ដែលឃើញមុខគាត់ដែរ?

ហ៊ុយ    ឃើញ! ឃើញមុខគាត់ប៉ុនមិនដែលនិយាយជាមួយគាត់ផង ។

វណ្ណៈ    ហើពូមើលពីក្រៅថាមនុស្សហ្នឹងមានចរិកយ៉ាងម៉េចដែរ?

ហ៊ុយ    មិនដែលដឹងយ៉ាងម៉េចដែរ ។

វណ្ណៈ    ទាហានពសេស៧០ពហ្នឹង ក្រៅពីតាពីន តាណាត ពូមានដែលឃើញមនុស្សណាម៉ោ ទំនាក់ទំនងជាមួយទាហានខាងហ្នឹងដែរ?

ហ៊ុយ    អត់ដឹង! ដឹងអី មានតាពួកកងពលប៉ុន្មាននាក់ហ្នឹង ។

វណ្ណៈ    នៅក្នុងកងពិសេសហ្នឹងមួយមានចែកជា...កងពល១២ណាស់ពូ មានចែកជាផ្នែកៗអីទៀតដែរ?

ហ៊ុយ    គ្មានចែកជាផ្នែកអីទៀតផង ។

វណ្ណៈ    មានប៉ុន្មានវរៈពូ? ម៉ាកងពលមានប៉ុន្មានវរៈសេនាធំ?

ហ៊ុយ    ដឹងប៉ុន្មានវរៈសេនាធំផង វាមិនស្គាល់គេ ដឹងបញ្ចូលកងណាៗខ្លះផង ។

វណ្ណៈ    ហើក្រោយម៉ោឆ្នាំ ក្រោយបែកភ្នំពេញហើយ គេមានដែលរើសទាហានចូលទៀតដែរ?

ហ៊ុយ    អត់ដឹង ។

វណ្ណៈ    ប៉ុន្តែចំនួនទាហាន ពីមុន៧៥ ហើយក្រោយ៧៥ យ៉ាងម៉េចដែរ ពេលណាច្រើនជាង?

ហ៊ុយ    ទាហានវាចុះច្បាំងកាលហ្នឹងវាអស់គ្នា វាខើចគ្នាដែរ នៅម៉ាក្រុមតា ៨-១០នាក់ ៩នាក់ ៧នាក់អីវ៉ុនហ្នឹង ។

វណ្ណៈ    ដឹងថាទាហាន១កងពលហ្នឹងមានប៉ុន្មាននាក់ដែរ?

ហ៊ុយ    អត់ដឹង ។

វណ្ណៈ    ខ្ញុំចង់បញ្ជាក់ពីរឿងចិនផ្តល់កាំភ្លើង ហើយក្រៅពីហ្នឹង មានចិនទំនាក់ទំនង ពូធ្លាប់ទំនាក់ទំនងជាមួយចិនអីដែរ?

ហ៊ុយ    អត់ដែលស្គាល់ចិនទេ ឃើញតាកាំភ្លើងវាហ្នឹង ។

វណ្ណៈ    ឃើញតាកាំភ្លើង អត់ដែលឃើញចិនម៉ោទេ?

ហ៊ុយ    អត់ទេ ។

វណ្ណៈ    ដែលឃើញចិនទៅណាម៉ោណាអីដែរ?

ហ៊ុយ    ចិនឃើញតែជិះឡាន ។

វិញម៉ោ ។

វណ្ណៈ ប៉ុន្មាននាក់ទៅពូ?

ហ៊ុយ បាទ! វៃជូនកាលពេលដែលខុចណឹងទៅបានវៃមួយចឹង បាទ! ។ ហើគាគេទៅទៀត គេឲ្យវៃទៀត ។ តាមវៃណឹងប្រហែលជា៥នាក់ ប៉ុនមិនដឹងជាអាយុប៉ុន្មានអីប៉ុន្មានអីទេ ព្រោះយប់ណាស់ ។ មានគាភ្លើងភ្លឺចឹង ព្រោះគេឲ្យវៃគេថាចឹង យើងមិនធ្វើតាមគេមិនបាន ព្រោះកន្លែងណឹងដូចជ្រាបហើយ មនុស្សរាប់រយនាក់ ទាំងអស់គ្នាគាប៉ុន្មាននាក់ណឹង ។ ហើប្អូនថ្លៃគេ២នាក់ អ្នកធ្វើការនៅក្នុងណឹងក៏គេចាប់ដាក់គុកសម្លាប់ចោល ចុះទម្រាំដូចខ្ញុំនេះវិន ។

វណ្ណៈ ពេលដែលពូធ្វើចឹងពូមានអារម្មណ៍យ៉ាងម៉េចដែរ ការណ៍ដែលពូធ្វើណឹង?

ហ៊ុយ បាទ! ខ្ញុំដូចបានខ្ញុំជម្រាបចឹងខ្ញុំថា ខ្ញុំជៀសវាងនៅកន្លែងណឹងមិនរួចទេ ព្រោះប្រហែលបងប្អូនគេ ក៏គេចាប់ដាក់គុកគេសម្លាប់ចោល ចុះទម្រាំដូចពួកខ្ញុំអស់នេះ ថ្ងៃណាមួយគេសម្លាប់ចោលអស់ទៀត ។ ប៉ុនដល់ក្រោយម៉ោគេចេះតាដកខ្ញុំ ៣ក្រុមឲ្យម៉ោធ្វើស្រែនៅខាងត្បូងដើងឯក ហើគេលែងឲ្យខ្ញុំដឹងពីរឿងអីទាំងអស់ រឿងអ្នកណាធ្វើអី គឺអ្នកណឹងដឹង ។ ហើខ្ញុំតាំងពីធ្វើ ឲ្យម៉ោធ្វើស្រូវក៏ខ្ញុំអត់ទៅអីអាញ៉ៅអាញ៉ៅនៅកន្លែងគេទេ ។

វណ្ណៈ ដកម៉ោឆ្នាំណាដែរពូ?

ហ៊ុយ ឆ្នាំ៧៨ណឹង ពាក់កណ្ដាលឆ្នាំ៧៨ ។

វណ្ណៈ ពូយល់ថា ដែលទង្វើពូធ្វើណឹង ធ្វើដើម្បីអីដែរ?

ហ៊ុយ **ខ្ញុំធ្វើនេះ គឺធ្វើដើម្បីរស់ខ្លួនឯងបាទ!** ។ មួយទៀតបើខ្ញុំរត់ខ្លាចគេសម្លាប់ម៉ែឪបងប្អូនខ្ញុំចោល ។ ហើមួយទៀតបើខ្ញុំមិនធ្វើគេសម្លាប់ខ្ញុំ ។ បានត្រឹមម៉ាធូខ្លួនបានត្រឹមគេដកខ្ញុំចេញឲ្យធ្វើស្រែ ។ ខ្ញុំដឹងថាបានរស់ខ្លះ ប៉ុនមិនដឹងថាថ្ងៃណាគេម៉ោចាប់ខ្ញុំយកទៅទៀត! ព្រោះវាមនុស្សគេលែងឲ្យចេញពីណឹងម៉ោទៀតហើយ ។ គានៅបានគាត្រឹមធ្វើស្រែណឹងទេ ចេញពីធ្វើស្រែណឹងអត់មានពេលទៅណាទេ ។ គាខុសគឺមានគាចូលគុកទេ ។

វណ្ណៈ ពេលពូនៅធ្វើការនៅកន្លែងណឹងចឹង ពូយល់ថាកន្លែងណឹងជាកន្លែងយ៉ាងម៉េចដែរ?

ហ៊ុយ កន្លែងណឹងជាកន្លែងសម្លាប់មនុស្សហ្នង គ្មានម៉ែឪណាជួយបានទេ ។

វណ្ណៈ ហើយពេលពូធ្វើចឹងពូមានអារម្មណ៍ថាពូបាត់បង់អីខ្លះ ពេលទៅធ្វើការណឹង?

ហ៊ុយ ខ្ញុំ ដូចខ្ញុំបានជម្រាបមុិញចឹង ខ្ញុំ...នឹកឃើញថានៅកន្លែងណឹងជៀសវាងស្លាប់មិនរួច ។ ដូចខ្ញុំបានជម្រាបពីមុនចឹង ថាដូចឃើញសុន សេន ម៉ោចឹងខ្ញុំចង់ដកខ្លួនចេញពីកន្លែងណឹងតែគាត់មិនឲ្យខ្ញុំចេញ ។ បើឲ្យខ្ញុំចេញពីណឹងម៉ោ ខ្ញុំក៏រួចខ្លួនតាំងពីណឹងម៉ោរហូត ។ ហីដល់គានៅៗណឹងកុំគាបានបែកទេ បើមិនបែកក៏ខ្ញុំស្លាប់ដែរអត់រស់ដែរ ជៀសមិនផុតទេរឿងស្លាប់នៅកន្លែងណឹង ។

វណ្ណៈ ចឹងពូយល់ថាអ្វីដែលពូធ្វើណឹងជាការខុសត្រូវរបស់ពូផ្ទាល់ឬក៏យ៉ាងម៉េច?

ហ៊ុយ **រឿងនេះខ្ញុំមិនមែនទទួលខុសត្រូវទេ ព្រោះរឿងគេបញ្ជាលើខ្ញុំ បើខ្ញុំមិនធ្វើគេសម្លាប់!** ។ អាណឹងមានតែ**ឌុច**ណឹងអ្នកទទួលខុសត្រូវរឿងទាំងអស់ណឹង ជាមួយគា**ហ៊ី** ជាមួយអីណឹង ។

វណ្ណៈ ក្រៅពីណឹងពូចង់ឲ្យអ្នកណាទៀតដែលទទួលចំពោះ...រឿង?

ហ៊ុយ ណឹងមានតែប៉ុន្មាននាក់ណឹង ។ចុះខ្ញុំទោចង់ធ្វើអីចឹង សូម្បីតែខ្ញុំនៅស្រុកភូមិខ្ញុំនៅផ្ទះសម្បែងខ្ញុំពីតូចម៉ោក៏ខ្ញុំមិនដែលចេះទាស់ទែងជាមួយអ្នកណាដែរ ។ ហីម៉ោនៅស្រុកនេះក៏គ្មានចេះទាស់ទែងអ្នកណាដែរ ។ ហីអាឡូវនេះក៏ចឹងដែរ អាឡូវបើថាជិះកង់ទោចម្ការទោអី ទោដើរទោណាណី ឲ្យគាគេក្រឡេកឃើញចេញម៉ោវិញអត់រួចទេ គេដឹកគេអីណឹង គេបញ្ឆោកទាល់តែស្រវឹងចង់ៗស្លាប់ ។ ហីផ្ទះខ្ញុំបើមានអីហូបវិញ មនុស្សមិនដឹងម៉ោពីណាទេ ។

វណ្ណៈ ចឹងដើម្បីឲ្យរួចនូវសំណាងដែលពូបាត់បង់ណឹងពូចង់បានអីវិញ ជាអារម្មណ៍របស់ពូ ពូចង់បានអី?

ហ៊ុយ ខ្ញុំគ្មានចង់បានអីទេ ។

វណ្ណៈ ពូ មានដែល...នៅក្នុងព្រឹត្តិការណ៍ទាំងអស់ដែលពូធ្លាប់ធ្វើ ធ្លាប់ឃើញ ពូចាំអីជាងគេហើយដែលធ្វើឲ្យពូនឹកឃើញឡើងវិញ?

ហ៊ុយ ខ្ញុំនឹកឃើញរឿងណឹង! បាទ! ។ បានថានឹកឃើញរឿងណឹងក៏ខ្ញុំនឹកឃើញរឿងថា ខ្ញុំមិនមែនអ្នកធ្វើដោយខ្លួនឯងទេ ។ បើខ្ញុំធ្វើខ្លួនឯងក៏ខ្ញុំមិនធ្វើដែរ ។

វណ្ណៈ ស្អីមួយដែលជម្រុញឲ្យពូនឹកឃើញអាអំពើដែលពូធ្វើណឹង? ហើយពេលណាដែរ?

ហ៊ុយ គឺគំនិតខ្លួនខ្ញុំដែលនឹកឃើញ មិនមែនចាំពេលណាទេ គឺនឹកឃើញរាល់ថ្ងៃហ្នឹង ។ នឹកឃើញថាខ្ញុំមិនមែនអ្នកធ្វើដោយខ្លួនឯង គឺម៉ោពីគេ ហើយច្បាប់គេកាលនោះមិនដូចច្បាប់អាឡូវ

ទេ។ បើដូចច្បាប់អាឡូវខ្ញុំម៉ោផ្ទះបាត់ហើយ ២៤ម៉ោងមិនទាន់ទេ អី២ម៉ោងមិនទាន់ទេខ្ញុំត្រូវតែម៉ោផ្ទះវិញ អត់ធ្វើទេ។ ហីដូច...គេចេះតាសួរខ្ញុំ ហីចុះម៉េចមិនចូលធ្វើការវិញ? ចូលធ្វើទាហានវិញ?។ ថាអ៊ើយ! អញមិនចូលធ្វើទេ មិននៅក្រោមបង្គាប់អ្នកណាទៀតទេ ណែ៎ក! ម៉ោចិញ្ចឹមកូន ចិញ្ចឹមចៅណោះ រួចការងារសំណាញ់មួយបង់ត្រីទៅ បានយកម៉ោឲ្យកូនចៅស៊ីទៅ ហីចឹងទេអាណាធំមួយនាំគ្នាជីកទៅវាសប្បាយហួសពេកហើយ ហើយយើងចង់ទៅរកម៉ែឪយើង យើងទៅស្រេចចិត្តយើងទៅ។

វណ្ណៈ ពូបើសិនជាអារម្មណ៍របស់ពូ ជាគំនិតរបស់ពូយល់ឃើញថាធ្វើយ៉ាងម៉េចដើម្បីឲ្យពូស្ងប់អារម្មណ៍ ហើយបាត់ឈប់នឹកឃើញអ៊ីដែលពូធ្វើណឹង?

ហ៊ុយ អាណឹងខ្ញុំបាន ដូចខ្ញុំជម្រាបចឹង ខ្ញុំថារឿងទាំងអស់ណឹង គឺម៉ោពីមេធំៗអស់ណឹងដែលធ្វើឲ្យខ្ញុំខុស។ ប៉ុន្តែខុសនេះក៏មិនមែនខ្ញុំធ្វើដោយខ្លួនឯងដែរ ម៉ោពីគេដែលជាអ្នកធ្វើបាបខ្ញុំណឹង។

វណ្ណៈ ចឹងមនុស្សទាំងអស់ណឹងគួរធ្វើយ៉ាងម៉េច ដើម្បីឲ្យពូ ក្នុងអារម្មណ៍របស់ពូ...?

ហ៊ុយ ច្បាប់ធ្វើម៉េចធ្វើទៅខ្ញុំអត់ដឹង!។

វណ្ណៈ ចុះបើសិនជាមានច្បាប់ មានអីគេឲ្យពូទៅនិយាយដើម្បីអស់អារម្មណ៍របស់ពូ ពូហ៊ានទៅនិយាយដែរ?

ហ៊ុយ និយាយយ៉ាងម៉េចក៏និយាយ ខ្ញុំមិនខ្លាចអីនិយាយទេ។

វណ្ណៈ តាំងពីពូធ្វើការនៅណឹងពូបាត់បងអ៊ីខ្លះ តាំងពីបម្រើនៅក្នុងសម័យខ្មែរក្រហមណឹងណាស់ ពីសាច់ញ្ញាតិសណ្ដាន ពីស្មារតីទាំងអស់ណឹង?

ហ៊ុយ បាទ! សាច់ញ្ញាតិរបស់ខ្ញុំគឺអស់ច្រើនដែរ គ្រាន់តាមារជីដូនមួយខ្ញុំអស់ប៉ុន្មាននាក់ សិតតាអ្នកធ្វើការនៅភ្នំពេញណឹង។ ហីមួយទៀតដូចខ្ញុំបានជម្រាបចឹង ក្រោយពីសុំ សុន សេន ហើយម៉ោ ប៊ុននិយាយក្រែងលំ មិន មិនជឿខ្ញុំទេនិយាយ!។ ថ្ងៃណឹងតាហ៊ាហៅខ្ញុំទៅ ហៅខ្ញុំទៅស្ដីឲ្យណឹង។ កាំភ្លើងអាកា ម៉ាដើមខ្ញុំកំពុងយាម ខ្ញុំប្រុងបាញ់ខ្លួនឯងចោល គេស្ដីឲ្យរហូតដល់ខ្ញុំយំ។ ចុះខ្ញុំកូនទា កូនអីអាទឹមញាស់ប៉ុនៗកដៃណឹង ទឹមញាស់ខ្សែភ្លើងណឹងឲ្យខ្ញុំចិញ្ចឹម។ ទាប៉ុន្មាន២០០នៅសល់តែ៨៤០។ ចុះបើខ្ញុំកិបម្សៅផង ហីអាអ្នកនៅជាមួយណឹង កិនម្សៅកិនអី ទៅដងកំពិសដងអីអាតាមលូតាមអីណឹង គ្នាឲ្យទំនេរទេ យកម៉ោ

ចឹញ៉ុមទាណឹង ។ ចឹញ៉ុមទាផង មាន់ផង ព្រាបផង អាពពែផង ចៀមផង ហីនៅតាមិនត្រូវចិត្តគេ គេស្ដីឲ្យ ។ ថ្ងៃណឹងបើខ្ញុំបាញ់ខ្លួនខ្ញុំចោលវាចប់ត្រឹមណឹងហើយ ។

វណ្ណៈ ហេតុអីបានជាពូចង់បាញ់?

ហ៊ុយ បាទ! ព្រោះគេស្ដីឲ្យខ្ញុំពេក គេថាខ្ញុំមិនចេះថែរក្សារបស់របរ បំផ្លាញ ។ គេហៅខ្ញុំសិតអាស្អី១ គាត់វាកាច គាត់ចេះដេរ ។

វណ្ណៈ អ្នកណាគេស្ដីឲ្យពូ?

ហ៊ុយ តាហ៊ីណឹង អនុប្រធានមន្ទីរណឹង ។ ខ្ញុំនឹកឃើញថាយំផងអីផង ថាបាញ់ចោលហើយមើលទៅ បើកសោរ២ផងហើយ នឹកឃើញថា អញបើបាញ់ខ្លួនអញ ម៉ែឪអញចៀសគេចាប់ដាក់គុកមុនរួច ព្រោះអាណឹងគេស្រាវតាមខ្សែណាស់ តាយើងខុសបាញ់ខ្លួនឯងគេស្រាវតាមខ្សែទៀត ។ ឈប់បាញ់ បិទសោរវិញ ។ កន្លែងអស់នេះមិនមែនកន្លែងល្អទេ កន្លែងតឹងតែងហួសហេតុហើយ សូម្បីតាអ្នកធ្វើការជាមួយគ្នាណឹង ក៏គ្មានអ្នកណាទុកចិត្តអ្នកណាដែរ ។ ខ្លាចរាយការណ៍ពីម្នាក់ៗណាស់ ។ ចឹងទេយាមដឹងតាយាម ម៉ោវិញស៊ីបាយ ដឹងស៊ីបាយទៅ គេឲ្យធ្វើអីធ្វើណឹង ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីចរិកលក្ខណៈមនុស្សម្នាក់ តាំងពីឌុច តាំងពីហ៊ី តាំងពីចាន់ តាមលំដាប់មួយៗ? ឥឡូវពូនិយាយពីឌុច មនុស្សឌុចជាមនុស្សយ៉ាងម៉េច?

ហ៊ុយ មនុស្សតាឌុចណឹងមនុស្សគាតគឺស្គាល់បុណ្យស័ក្កជាស្គាល់មនុស្សដូចគ្នា គាត់ណឹងដំណើរគាត់ធ្វើ ចង់ធំជាង ប៉ុល ពត ណោះ ។ ហីតាហ៊ីនេះ តាហ៊ីមិនចង់ធំប៉ុន្មានទេ ប៉ុនគាត់កាចដែរ ។ បើថាស្ដីឲ្យអ្នកណា ស្ដីឲ្យគ្មានដឹងអីទេ ។ ហីតាចាន់អីខ្ញុំមិនដឹងទេ ព្រោះគាត់នៅក្រសួងខុសគ្នា ខាងផ្នែកសួរចម្លើយ ។

វណ្ណៈ នៅណឹងគេហៅក្រសួងដែរ?

ហ៊ុយ បាទ! ខាងផ្នែកសួរចម្លើយ ។

វណ្ណៈ ហីចុះហ៊ុយអី?

ហ៊ុយ តាហ៊ុយគាត់ផ្នែកធ្វើស្រែនៅព្រៃស ។

វណ្ណៈ ព្រៃស អាណឹងមានលេខដែរ?

ហ៊ុយ បាទ! អាណឹងគេហៅ២៤ ។

វណ្ណៈ ស-២៨?

ហ៊ុយ បាទ! កន្លែងធ្វើស្រែ គេហៅស-២៨ ។

វណ្ណៈ កន្លែងហ្នឹងម៉េចបានគេដាក់... ធ្វើស្រែហ្នឹងពីណាយកទៅធ្វើស្រែនៅហ្នឹង?

ហ៊ុយ កន្លែងហ្នឹងគេរៀបចំចឹងហ្មង អ្នកខុសវិន័យគ្រប់ក្រសួងគ្រាប់អី តាខុស ដូចថាខុសល្មមៗ ដែលគេថាមិនទាន់ឲ្យជាប់គុកគេយកឲ្យទៅធ្វើស្រែ ។ ហីបើថាធ្វើស្រែហ្នឹងហើយនៅតាមាន កំហុសទៀតចូលគុក ។

វណ្ណៈ គុកហ្នឹង ចូលគុកនៅណាវិញ?

ហ៊ុយ ចូលគុកនៅទួលស្លែងហ្នឹង ។

វណ្ណៈ ចឹងមុនដំបូងគេបញ្ជូនទៅ...?

ហ៊ុយ បញ្ជូនអាអ្នកល្មមៗ តាអ្នកមិនខុសធំទេណាស់ គេបញ្ជូនទៅហ្នឹង ។ ដល់នៅហ្នឹងធ្វើការមិនកើត នៅវិលទទឹងជាមួយគេ គេបញ្ជូនឡើងម៉ោចូលគុកវិញ ។

វណ្ណៈ ប៉ុនដាទូទៅអ្នកទោសមានដែលចូលស-២១ ហើយបានចូលទៅធ្វើស្រែហ្នឹងប្អត់?

ហ៊ុយ អត់ទេ ។

វណ្ណៈ ច្រើនតាយ៉ាងម៉េច?

ហ៊ុយ ច្រើនតាម៉ោ ចូល អ្នកដែលមានទោសគឺចូលហ្នឹងបាដោយ ហីអ្នកដែលខុសល្មមៗដូចខ្ញុំបាននិយាយចឹងគឺទៅធ្វើស្រែ ។

វណ្ណៈ ហីចុះប៉េងនោះ?

ហ៊ុយ ប៉េង ប្រធានការពារនៅកន្លែងគុកហ្នឹង ។

វណ្ណៈ យ៉ាងម៉េចដែរប៉េង?

ហ៊ុយ ប៉េងហ្នឹងគេពូកែអែបអប ជាមួយឌុច ហីហ៊ាហ្នឹង ។ វាពូកែអែបអបជាមួយវាស្រឡាញ់បុណ្យស័ក្តជាង ។

វណៈ ពេលដែលពូធ្វើការនៅហ្នឹងគេមានវិន័យគេមានរបៀបរបបឲ្យយើងហូបចុកអីយ៉ាងម៉េចដែរនៅហ្នឹង?

ហ៊ុយ ហូបចុក ខាងពួកខ្ញុំខាងផ្នែកការពារហូបចុកជាមួយពួកការពារ ហីពួកគេសួរចម្លើយគេស៊ីខាងពួកគេសួចម្លើយហ្នឹងទៅ ។ ហីតាឌុចគេ ជាមួយតាហ៊ា តាអីមាំគុគេហ្នឹងទៅ ។

ជូនកាលតាហ៊ីស៊ីដោយខ្លួន តាឌុចស៊ីដោយខ្លួនទៅ ។ ប៉ុន្ត២នាក់ហ្នឹងក៏នៅប្រកាន់បក្សពួកគ្នាដែរ ចង់ប្រឆាំងគ្នាញឹកដែរ ។

វណ្ណៈ ប្រឆាំងយ៉ាងម៉េចពូ?

ហ៊ុយ ដឹងប្រឆាំងរឿងអីគេទេ ព្រោះតាហ៊ីនេះកាន់ជើងខាងពួកម្ខាង ខាងពួកខ្ញុំណាស់ ។ តាឌុចគេកាន់ជើងម្ខាងខាងពួកគេ ។

វណ្ណៈ ពូតាហ៊ីមានអ្នកណាខ្លះ?

ហ៊ុយ ពួកតាហ៊ីខាងផ្នែកការពារ ។

វណ្ណៈ ពួកឌុច?

ហ៊ុយ តាឌុចពួកសួរចម្លើយ ហ៊ីដែលគណៈកម្មាធិការគេខាងផ្នែកសួរចម្លើយ ខាងពួកសរុបអីគេហ្នឹង ខាងពួកតាឌុចហ្នឹង ។ ហ៊ីតាពួកគេរាយការណ៍អី តាឌុចហ្នឹងជឿហើយ អត់មានជឿពីតាហ៊ីហ្នឹងទេ ។ តាហ៊ីរាយការណ៍អត់សូវជឿទេ ។ បើពួកតាចាន់ពួកអីគេធ្លាប់នៅជាមួយគ្នា ពីមុនៗហ្នឹងម៉ោគេជឿគ្នាគេ ។

វណ្ណៈ ខ្ញុំចង់ឲ្យពូនិយាយពីរឿងវៀតណាមមួយទៀត? ពូទៅវៃជាមួយវៀតណាមហ្នឹងនៅឆ្នាំណាដែរ?

ហ៊ុយ ខ្ញុំអត់មានទៅវៃផង ។ អត់មានទៅវៃជាមួយវៀតណាមផង ។

វណ្ណៈ ចឹងពូដឹងថាមានសង្គ្រាមជាមួយវៀតណាមហ្នឹងនៅពេលណា?

ហ៊ុយ មានសង្គ្រាមជាមួយវៀតណាមឆ្នាំ៧៥ ។

វណ្ណៈ ពេលបែកភ្នំពេញហើយ ឬពេលក្រោយភ្នំពេញ?

ហ៊ុយ អូស៎! ចូលឆ្នាំ៧៨ ៧៧ហើយ ៧៨ វៃវៀតណាម ។

វណ្ណៈ ពូដឹងថាគេវៃហ្នឹងយ៉ាងម៉េចដែរ?

ហ៊ុយ មិនដឹង ។

វណ្ណៈ ប៉ុនពូយ៉ាងម៉េចបានដឹងថាមានវៃជាមួយវៀតណាម?

ហ៊ុយ វៃជាមួយវៀតណាម គេថាវៀតណាមឈ្លានពានចូលទឹកដីយើង ។

វណ្ណៈ វៀតណាមខាងណា វៀតណាមខាងជើង ឬខាងត្បូង?

ហ៊ុយ	វៀតណាមខាងត្បូង ។ អ្នកទាំងត្បូងទាំងជើងណឹង ប៉ុនដឹងខាងណាទេ ខ្ញុំមិនដឹងដែរគេថា វៀតណាមៗ ។

វណ្ណៈ	ហីចឹងពូមានបានឡើងវៃនឹងគេដែរចឹង?

ហ៊ុយ	អត់បានទៅ ចុះសុំគេមិនឲ្យទៅផង បានអត់បានទៅណឹង ។

វណ្ណៈ	ហីពេលណឹងពូមានឮទាហាននៅក្នុងជួរណឹង ក្រោយ៧៥ហើយមានទំនាស់គ្នាទេ ពួកទាហាន ពួកអីណឹងមានដែលឮទាស់គ្នា ថាបង្កើតបក្សបង្កើតអី ក្បត់គ្នាទៅវិញទៅមោ មានដែលឮ ថាមានទេ?

ហ៊ុយ	បាទ!

វណ្ណៈ	ពូឮយ៉ាងម៉េច?

ហ៊ុយ	ឮថាពួកខាងភូមិភាគបូព៌ាម៉ាបែក ពួកខាងភូមិភាគពិសេសម៉ាបែក ហីពួកខាងជើងភ្នំពេញ នេះម៉ាប៉ែកទៀត ។

វណ្ណៈ	ហើយមានយ៉ាងម៉េចទៀតពូ?

ហ៊ុយ	ដឹងតាប៉ុនណឹង ។

វណ្ណៈ	បូព៌ាពូមានដឹងថាពីណាគេដឹកនាំនៅបូព៌ាណឹងទេ?

ហ៊ុយ	ខាងបូព៌ា តាសោភឹម ។

វណ្ណៈ	ហីកាលណឹងគេឈ្លោះគ្នា ហើយមានព្រឹត្តិការណ៍អី នៅពេលឈ្លោះគ្នាណឹងទៅ?

ហ៊ុយ	មិនដឹង ។

វណ្ណៈ	ពូមានដែលឃើញតាភឹមណឹង សោភឹម ណឹងដែរ?

ហ៊ុយ	អត់ដែលស្គាល់! ដែលស្គាល់តែ... **ចាន់ចក្រី** ។

វណ្ណៈ	ពូស្គាល់របៀបម៉េច តាមរយៈយ៉ាងម៉េចដែរ?

ហ៊ុយ	ស្គាល់! ព្រោះគាត់ កាលប្រកាសកងពលពួកខ្ញុំគាត់ម៉ោអ្នកប្រកាសកងពលណឹង ៧០៣ ។

វណ្ណៈ	ប្រកាសកងពលនៅឆ្នាំណាដែរពូ?

ហ៊ុយ	ប្រកាសតាំងពីឆ្នាំប៉ុន្មាន ៧៤-៧៥ណោះ ។

វណ្ណៈ	នៅពេលមុនបែកភ្នំពេញឬក្រោយពេលបែកភ្នំពេញ?

ហ៊ុយ	តាំងមុន ។

វណ្ណៈ នៅឆ្នាំណាដែរ?

ហ៊ុយ អាឆ្នាំ៧៥អី ៧៦-៧៧អី ។

វណ្ណៈ ហើពូមានដែលដើរជាមួយចិនដែរ?

ហ៊ុយ អត់!

វណ្ណៈ ចិនគេជិះឡានទៅណាខ្លះ?

ហ៊ុយ ទេដឹងអីគេ គេបេះតាជិះតាមផ្លូវណឹង ។

វណ្ណៈ គេម៉ៅក្មុងន័យអីដែរចិន?

ហ៊ុយ មិនដឹងគេដែរ ។

វណ្ណៈ ដែលម៉ៅទួលស្លែងដែរ?

ហ៊ុយ អត់ទេ ។

វណ្ណៈ ច្រើនតាទៅណាពូឃើញណឹង?

ហ៊ុយ ចុះឃើញតា តាមផ្លូវដឹងទៅណាគេ ។

វណ្ណៈ ពូមានដែលនាំចិនទៅកន្លែងណាអីកន្លែងណាទេ?

ហ៊ុយ អត់ទេ អត់ដែលផង ។

វណ្ណៈ ចឹងខ្ញុំចង់បញ្ជាក់ឡើងវិញ ឲ្យពូនិយាយពី ពូឈ្មោះអីហើយ នៅសព្វថ្ងៃណឹងនៅភូមិអីដែរ?

ហ៊ុយ ខ្ញុំឈ្មោះ ហ៊ឹម ហ៊ុយ នៅភូមិអន្លង់តាសាន ឃុំព្រែកស្តី ស្រុកកោះធំ ។សព្វថ្ងៃធ្វើចម្ការ ។

វណ្ណៈ អាយុប៉ុន្មានឆ្នាំហើយពូ?

ហ៊ុយ អាយុ៤៥ឆ្នាំ ។

វណ្ណៈ គិតជាឆ្នាំវិញពូកើតនៅឆ្នាំណាដែរ?

ហ៊ុយ ឆ្នាំមមែរ ។

វណ្ណៈ ឆ្នាំមមែរ! ហើយគិតជាលេខ ឆ្នាំ?

ហ៊ុយ លេខ ឆ្នាំ៥ ៤ ។

វណ្ណៈ ស្រុកកំណើតដែលកើតជាណឹងនៅកន្លែងណាដែរ?

ហ៊ុយ នៅឃុំក្បាលជ្រោយ ឃុំពោធិបាន ស្រុកកោះធំណឹង ។

វណ្ណៈ ចឹងអគុណហើយពូដែលបានផ្តល់ឲ្យខ្ញុំសម្ភាន៍ ។

# បទសម្ភាសន៍បន្ថែម

វណ្ណៈ ខ្ញុំពូចង់ឲ្យពូនិយាយពីរឿងចិន ទាក់ទងរឿងចិន?

ហ៊ុយ កាលណោះកាលខ្ញុំនៅ៧០៣ណោះ គាណាគគេឲ្យកងវរៈរើសមនុស្សប៉ិន្នានទេ ដូច៦នាក់អី មិនដឹងទេ ឲ្យការពារវិស្វករចិន ទៅមើលអគ្គិសនី គេថាគេទៅតភ្លើង ទៅធ្វើម៉ាស៊ីននៅអាគីរីរម្យអីនេះ នៅអាគីរីរម្យណឹងហើយបានទៅ កំពត អ្ហាស់! កំពង់សោមអីណឹង ។ ជូនគេទៅនេះចឹង ហីដល់ហើយ ។

វណ្ណៈ អាណឹងឆ្នាំណាដែរ?

ហ៊ុយ អាណឹងឆ្នាំ៧៦ ។ ដល់ហើយជូនទៅណោះ ទៅបាត់ដំបងទៅមើល ទៅតាម តាំងពីផ្លូវពោធិសាត់រហូត ជូនមើលអាម៉ាស៊ីនភ្លើងគេណឹង ។ ហីទៅដល់ ជូនគេបានត្រឹមៗអាកន្លែងកែស្នាក់នៅណឹង ដល់ពេលនេះគេទៅខ្លួនគេ ។ គេទៅដូចថាកន្លែងស្នាក់នៅកន្លែងណាមួយយើងនៅណឹងទៅ ហីគេទៅដើរមើលអាម៉ាស៊ីនណឹងខ្លួនគេ ។ ដល់ពេលនេះគេម៉ោវិញម៉ោគេឲ្យយើងការពារគេទៅទៀត ទៅអាកន្លែងស្នាក់មួយទៀត ដូចថាបាត់ដំបងចឹងគេទៅមើលទៅ គេម៉ោវិញម៉ោ យើងទៅការពារគេទៀតទៅ ។

វណ្ណៈ ហី...?

ហ៊ុយ ទៅ ទៅជាមួយគាណាគណឹង គាណាគកងពលណឹង ។ គាណាគណឹងទៅជាមួយចិន ដើរជាមួយចិន ពួកខ្ញុំខាងទាហានគ្នា៦នាក់នេះ ជិះឡានមួយផ្សេងទៀតទៅ អាឡានអា កាត់ៗចិនណឹង អាលាក់ចង់ងាប់ ដាក់សាំងម៉ាពុយតាមឡានណឹង ជិះអាតាមក្រោយគេណឹងក្តៅចង់ងាប់រហូត បានឈប់ម៉ាកន្លែងៗអរចង់ងាប់ ។

វណ្ណៈ គេធ្វើអគ្គិសនីណឹង គេធ្វើនៅកន្លែងណា គេធ្វើ ធើអីអាណឹង?

ហ៊ុយ អគ្គិសនីចាស់ៗពីមុនណឹង ។ ដូចថាអគ្គិសនីនៅគីរីរម្យណឹងវាខូចអី គេទៅមើលគេប្រុងធ្វើឲ្យដើរវិញ ។ ហីនៅកំពង់សោម... ដឹងអគ្គិសនីយ៉ាងម៉េចខ្លះក៏ខ្ញុំ កាលណឹងមិនដែលស្គាល់មិនដែលអី គេឲ្យទៅចេះតាទៅ ។

វណ្ណៈ ខ្ញុំឲ្យពូនិយាយអ៊ីដែលពូនឹកឃើញ ពេលដើរជាមួយចិនណឹងណាស់ ពូនឹកឃើញអី ហើយសកម្មភាពអីខ្លះដែលចិននាំពូទៅណាកន្លែងណា?

ហ៊ុយ អត់ដឹងអី ដឹងតាគេថាមើល ធើអគ្គិសនីអីណឹង ខ្ញុំដឹងអីខ្ញុំកាលណឹង ។

វណ្ណៈ ហើតាណាគមានប្រាប់ឲ្យពូធ្វើយ៉ាងម៉េចអីយ៉ាងម៉េចក្នុងការដើរជាមួយចិនណឹង?

ហ៊ុយ អត់ទេគេថាការពារគេ តាផ្លូវខ្លាចទាហាន ខ្លាចអីបាញ់ គ្រាន់តែការពារតាមផ្លូវ ។ ដល់ពេលគេបើកឡានមុនទៅ យើងឡានទៅតាមក្រោយគេទៅ ។

វណ្ណៈ ទាហានណឹងម៉ោចាស់ ឬក៏ក្មេងពួកចិនម៉ោណឹង?

ហ៊ុយ សិតតែចាស់ៗ អាយុ៥០-៦០ ។

វណ្ណៈ ចិនក្រៅពីគេម៉ោធ្វើនេះណឹង ពូមានដឹងថាគេម៉ោ... ក្រៅពីម៉ោធ្វើអគ្គិសនី មានចិនម៉ោធ្វើអីផ្សេងទៀតទេ?

ហ៊ុយ អត់ដឹង ។ គ្រាន់តាឃើញ ដើរតាមផ្លូវណឹង ឃើញគេជិះឡានអីណឹង ។

វណ្ណៈ ជិះឡាននៅកន្លែងណា នៅម្តុំណា?

ហ៊ុយ នៅអាខាងមុខទួលស្លែងណឹង ផ្លូវខាងកើតណឹង ផ្លូវធំណឹង ។ ឃើញគេជិះជើង ត្បូងៗណឹងតាមណឹង ។

វណ្ណៈ ពូនៅកងការពារណឹងមានគ្នាប៉ុន្មាននាក់ដែរពូ?

ហ៊ុយ កាលដែលខ្ញុំនៅណឹងគ្នាប៉ុន្មានទេ ប្រហែលជាគ្នា៥០-៦០នាក់ ។ កាលមុនគ្នាម៉ាកានរ កាលមុនគ្នាប៉ុន្មានរយនាក់ណោះ អស់ទាំងកងរយ អស់ទាំងកងអីណឹង ។ ដល់ហើយបានគេចាត់តាំងខ្ញុំណេ្តាះអាសន្នឲ្យ បណ្តោះអាសន្នអត់មានកងរយណឹង ដល់ហើយនៅសល់គ្នាប៉ុន្មានជាង៦០នាក់ណឹង ។

វណ្ណៈ ខ្ញុំចង់សួរពីកងរយ ហើយនិង កងហារ ។ កងរយមានន័យថាយ៉ាងម៉េច កងហារមានន័យថាយ៉ាងម៉េច?

ហ៊ុយ កងរយគ្នា១០០នាក់ កងហារគ្នា៣ក្រុមណឹង ។

វណ្ណៈ ៣ក្រុមប៉ុន្មាននាក់ហើយ?

ហ៊ុយ មិនដល់៣០នាក់ ថា៣០នាក់ចុះ ។

វណ្ណៈ ម៉ាកងហារ ហ៊ីនិង ម៉ាកងអនុសេនាតូចឬជាកងអនុសេនាធំ?

ហ៊ុយ អនុសេនាតូចម៉ាកងហារ អនុសេនាធំម៉ាកងរយ ។

វណ្ណៈ ចឹងពីរណឹងមានន័យស្មើគ្នា ។

ហ៊ុយ បាទ! ។

វណ្ណៈ ចឹងពូមានចង់អីថែមទៀតទេ រឿងចិនណឹង?

ហ៊ុយ ដឹងមានអីថែម បើមិនរៀនគេ វា... មិនដឹងគេធ្វើអីគេ ដឹងថាគេទៅមើលអក្សរនឹណឹងគេទៅ ។

វណ្ណៈ ចឹងអរគុណពូម្តងទៀត ។

នាន នៅពេលដែលបងចូលខាងកងសេុិបការណ៍ណឹងនៅឆ្នាំដែរ?

ហ៊ុយ អាណឹងឆ្នាំ៧៥ ។

នាន ហើបន្ទាប់ម៉ោបងថានីរសាររទៅឌុបកង់ម៉ោ នៅឆ្នាំណា?

ហ៊ុយ អាណឹងឆ្នាំ៧៧ហើយ ។

នាន ដើមឆ្នាំ អីចុងឆ្នាំ?

ហ៊ុយ ដើមឆ្នាំ ។

នាន ហើនៅមួយទៀតនៅពេលដែលវៃនៅកោះអន្ទង់ចិននៅឆ្នាំណា?

ហ៊ុយ អាណឹងឆ្នាំ៧៥ដែរ ។

នាន ៧៥ ដើមឆ្នាំអីចុងឆ្នាំ?

ហ៊ុយ ឆ្នាំ៧៤-៧៥ ។

នាន ហើខ្ញុំសុំសួរមួយទៀតនៅពេលដែលបងកំពុងតែហាត់នៅព្រៃកគូច បងបានឃើញអ្នកដែលស្គាល់កនាជាប់ខ្នោះគេយកទៅដាក់នៅក្នុងចេតីយ៍ណឹង តើគេដាក់របៀបម៉េច ហើយក្នុងពេលឆ្នាំណាដែរ?

ហ៊ុយ អាណឹងឆ្នាំ៧៤

នាន ចឹងនៅក្នុងចាយដីណឹងគេធ្វើជាគុក?

ហ៊ុយ ទេមិនដឹងអីគេ គេដាក់ក្នុងចាយដីនៅណឹងម្នាក់ឯង ។

នាន ហើរូបរាងយ៉ាងម៉េចដែរ?

ហ៊ុយ រូបរាង មានតាស្លៀកខោខ្លីមួយ ។

នាន អត់មានពាក់អាវទេ?

ហ៊ុយ អត់ ។

នាន ហើ មុិញខ្ញុំពូបងមិនទាន់និយាយច្បាស់ពីកងសម្រុក ហើនិងកងថ្មើជើងណឹងខុសគ្នាយ៉ាងម៉េច

កងសម្រុកណឹងគេឲ្យគួនាទីវ៉ាយ៉ាងម៉េចពេលចូលវៃ?

ហ៊ុយ កងសម្រុកណឹងពេលដឹងថាវៃកន្លែងណា ឲ្យកង ម៉ាកងណឹងទៅវៃហ្នឹង វៃទីតាំងមួយណា ខ្ញុំបានជម្រាបហើយដែរមុននោះ ។

នាន ហើចុះកងផ្សេងទៀតនោះ?

ហ៊ុយ កងថ្មើរជើងផ្សេងគឺ ខ្សែត្រៀមម៉ាខ្សែត្រឹមម៉ាណ គេឲ្យទៅវៃត្រឹមម៉ាណដាក់ម៉ាខ្សែត្រឹមណឹង សម្រាប់ជាមួយទាហានត្រឹមណឹង ។

ណាក់ ហើមានសង្គ្រាមរបៀបម៉េចបានគេឲ្យកងសម្រុកទៅវៃ?

ហ៊ុយ កងសម្រុកណឹងដូចថាទីតាំងគេចឹងណាស់ ទីតាំងទាហានម៉ាបន្ទាយចឹងគេឲ្យទៅយកការណ៍វៃបន្ទាយណឹង ។

នាន ហើដល់នៅពេលខ្ញុំចាំបានបងនិយាយ១ទៀតថា ពេលដែលបងចូលដល់ណឹង បានទៅដល់សាលារៀនមួយនៅខាងជើងពេទ្យចិន បងនិយាយណាស់?

ហ៊ុយ អត់មានសាលារៀននៅមន្ទីរពេទ្យណា!

នាន នៅ មាននិយាយ បងនិយាយថាតម្រៀបជួរ តម្រៀបជួរហើយគេបោកគ្រាប់បែក ។

ហ៊ុយ មន្ទីរពេទ្យ!

នាន ណឹងហើយមន្ទីរពេទ្យ មន្ទីរពេទ្យចិន ខាងជើងណឹងណាស់ ។

ហ៊ុយ អត់ទេ ។ អាមន្ទីរពេទ្យចិននៅខាងកើតផ្លូវណាស់ ហើអាសាលា...ខ្ញុំទើបតេដឹងអាឡូវដែរ ណឹងថាអាណឹងមន្ទីរពេទ្យតើ បាទ! ។ បានគេថាអាណឹងមិនមែនទេកន្លែងសាលារៀនតើ ។ ហើនៅអាខាងជើងសាលារៀនណឹង អាផ្លូវ... ។

នាន ដល់ពេលបែកណឹងបងចូលទៅដល់ណឹង?

ហ៊ុយ បាទ!

នាន ដល់ពេលទៅត្រូវរបួសត្រូវកន្លែងណា?

ហ៊ុយ ត្រូវកន្លែងណឹង ។

នាន ត្រូវកន្លែងណឹងដែរ! ហើលួន ដល់ពេលត្រឡប់ម៉ោវិញតាមផ្លូវណា?

ហ៊ុយ លួន ទៅចឹងទៅលិចទៅ ទៅចូលផ្ទះគេទៅ ។

នាន ម៉ោខាងណាវិញ ខាងជើង?

ហ៊ុយ ទៅលិច ណោះទៀត ដឹងកន្លែងណាកន្លែងណា ខ្ញុំមិនស្គាល់ផង ។

នាន ចឹងបានសេចក្តីថា ក្រុមរបស់បងណឹងបានទៅដល់ពេទ្យចិនណឹងហ្នឹង?

ហ៊ុយ បាទ!

នាន ខ្ញុំមានតែប៉ុណ្ណឹង! ហើក៏គ្រាន់តែសុំបញ្ជាក់ឆ្នាំ ខែ តែប៉ុណ្ណឹង ។

វណ្ណៈ ចឹងអរគុណហើយពូ ។

ចប់

## បទសម្ភាសន៍ជាមួយ សឹម សុរិយា ប៉ាន់ ឫទ្ធី ខណ្ឌាត

ហ៊ុយៈ គេបង្រៀនពីទស្សនៈបដិវត្តន៍ឲ្យយល់ច្បាស់ពីមាគ៌ារបស់បក្ស ។ ១ទៀតឲ្យខំបម្រើការងាររបស់បក្ស ។ ១ទៀតយើងតស៊ូវណ្ណៈកម្មករកសិករ ផ្តាច់ការចំពោះមូលធននិយមសក្តិភូមិ ប្រតិកិរិយា ។ ខំពង្រឹងគោលជំហរគ្រប់គ្នាដើម្បី តស៊ូដើម្បីរំដោះជាតិ ទឹកដីមាតុភូមិ ។ ហើក្រោយម៉ោទៀតគេឲ្យខំប្រឹងបោសសម្អាត កម្ទាំងបង្កប់ផ្ទៃក្នុងបដិវត្តន៍ ឲ្យមើលឲ្យច្បាស់ចំពោះខ្មាំងសត្រូវ ។ បើអ្នកណាប្រឆាំងជាមួយបដវត្តន៍ត្រូវកម្ទេចចោល ។ សូម្បីតែការណែនាំរបស់គេ បងប្អូនម៉ែឪក៏ដោយ ក៏វាអត់ឲ្យថាជា«ឪពុកម្តាយ ជាបងប្អូនដែរ ។ គឺគេនិយាយថា«ក្បាលអ្នកណា គឺសក់អ្នកណឹង» ។